ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## គកប/គករ

សម្រាប់

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

នីតិកាលទី៥ ឆ្នាំ ២០១៣

# មាតិកា

ទំព័រ

**គោលបំណង** ..........

**I. ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត** .......... ១

១- ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត .......... ១

២- បរិវេណខាងក្នុង .......... ១

៣- បរិវេណខាងក្រៅ .......... ១

៤- ភ្នាក់ងារសន្តិសុខបោះឆ្នោត .......... ២

៥- វិធានការសន្តិសុខ .......... ២

ក- វិធានការសម្រាប់ការិយាល័យបោះឆ្នោត .......... ២

ខ- វិធានការសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោត .......... ៣

**II. គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គកប/គករ)** .......... ៤

១- សមាសភាព គកប / គករ .......... ៤

២- ការទទួលខុសត្រូវ និងភារកិច្ចរបស់ គកប / គករ .......... ៤

**III. ការត្រួតពិនិត្យវត្តមានសមាសភាព គកប/គករ សម្ភារ ឯកសារ និងទីតាំងការិយាល័យបោះឆ្នោត** .......... ៥

១- ការត្រួតពិនិត្យវត្តមាន គកប / គករ .......... ៥

២- ការទទួល និងការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត .......... ៦

ក- សម្ភារ ឯកសារបោះឆ្នោតដែល គកប / គករ ត្រូវទទួល .......... ៦

ខ- ការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត .......... ៨

គ- ក្រោយការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត .......... ៩

ឃ- ការរក្សាការពារសម្ភារ ឯកសារបោះឆ្នោត .......... ៩

៣- ការពិនិត្យទីតាំងការិយាល័យបោះឆ្នោត .......... ៩

៤- ការប្រើប្រាស់បញ្ជីបោះឆ្នោត .......... ១១

**IV. ការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅថ្ងៃបោះឆ្នោត** .......... ១១

១- ការរៀបចំសម្ភារ ឯកសារបោះឆ្នោត និងការពន្យល់ណែនាំដល់តំណាងគណបក្ស អ្នកសង្កេតការណ៍ .......... ១១

ក- ការរៀបចំសម្ភារតាមគំរូប្លង់ ............ ១១
ខ- ការពន្យល់ណែនាំដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍....... ១២
២- ភារកិច្ចរបស់ គកប នៅចន្លោះពីម៉ោង ៦:០០ ព្រឹក ដល់ម៉ោង ៦:៣០ ព្រឹក នៃថ្ងៃបោះឆ្នោត........... ១៣
៣- ភារកិច្ចរបស់ គកប នៅចន្លោះពីម៉ោង ៦:៣០ ព្រឹក ដល់ម៉ោង ៧:០០ ព្រឹក នៃថ្ងៃបោះឆ្នោត............ ១៤
ក- ការពិនិត្យកញ្ចប់សន្លឹកឆ្នោត ............ ១៥
ខ- ការពិនិត្យ និងបង្ហាញត្រាសម្ងាត់ ............ ១៥
៤- ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការប្រើប្រាស់សម្រាប់ការបោះឆ្នោត ............ ១៦
៥- ពេលបោះឆ្នោត ចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀល............ ១៩
៦- ការងាររបស់ប្រធានក្នុងពេលមានករណីផ្សេងៗកើតឡើងនៅពេលបោះឆ្នោត............ ២៥
ក- ករណី អ្នកបោះឆ្នោតមានស្នាមទឹកខ្មៅលុបលាងមិនជ្រះជាប់នៅលើម្រាមដៃ............ ២៥
ខ- ករណី លេខាធិការរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមិនឃើញ............ ២៦
គ- ករណី អ្នកបោះឆ្នោតមានបំណងស៊ុកសន្លឹកឆ្នោតលើសពីមួយ (១) សន្លឹក ឬ/និងសន្លឹកឆ្នោតក្លែងក្លាយ ...... ២៦
ឃ- ករណី អ្នកបោះឆ្នោតពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន............ ២៦
ង- ករណី អ្នកបោះឆ្នោតពិការភ្នែកទាំងសងខាង............ ២៧
ច- ករណី អ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប៉ុនប៉ងចង់ឃើញអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រគណបក្ស.... ២៧
ឆ- ករណី សន្លឹកឆ្នោតខូច ឬរហែកដោយអចេតនា............ ២៨
ជ- ករណី មានការជំទាស់ពីតំណាងគណបក្សនយោបាយណាម្នាក់ក្នុងពេលបោះឆ្នោត............ ២៨
ឈ- ករណី មានអ្នកបោះឆ្នោតរំខានធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត ............ ២៩
ញ- ករណី កិច្ចប្រតិបត្តិការបោះឆ្នោតត្រូវរំខានដល់កម្រិតដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបានតទៅទៀត ...... ២៩
ដ- ករណី ការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោងបី ( ៣:០០) រសៀល ហើយនៅតែមានអ្នកបោះឆ្នោត ...... ២៩
ឋ- ករណី ប្រធានសន្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន............ ៣០
ឋ-១ ករណីមិនបើកការិយាល័យបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត ............ ៣០
ឋ-២ ករណីការិយាល័យបោះឆ្នោតមិនបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត ............ ៣០
ឋ-៣ ករណីកាលៈទេសៈមានអាសន្នកើតឡើងក្រោយពេលបិទការបោះឆ្នោតតែសម្ភារឯកសារត្រូវខូចខាត ...... ៣១
ឋ-៤ ករណីកាលៈទេសៈមានអាសន្នកើតឡើងក្រោយពេលបិទការបោះឆ្នោតតែសម្ភារឯកសារនៅល្អ ............ ៣១
V. ការបិទការបោះឆ្នោត នៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត............ ៣២
១- ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច... ៣៣
២- រូបមន្តផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត............ ៣៣
៣- កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងការប្រើប្រាស់ ............ ៣៤

៤- ការវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " (មិនទាន់បិទភ្ជិតការសុវត្ថិភាព) ....... ៣៤

៥- ការរៀបចំទុកដាក់សម្ភារ ឯកសារនៅសល់ផ្សេងទៀត ....... ៣៦

**VI. ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត** ....... ៣៦

១- ការចាត់ចែងរៀបចំបន្ទប់រាប់សន្លឹកឆ្នោត ....... ៣៧

២- វិធានការចំពោះករណីអ្នកធ្វើសកម្មភាពមិនប្រក្រតីដើម្បីចង់ដឹងអ្នកបោះឆ្នោតបានបោះឆ្នោតឱ្យគណបក្សណាមួយ ....... ៣៧

៣- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ....... ៣៨

ក- សន្លឹកឆ្នោតបានការ ....... ៣៨

ខ- សន្លឹកឆ្នោតមិនបានការ ....... ៣៨

ខ-១ សន្លឹកឆ្នោតមិនផ្លូវការ ....... ៣៨

ខ-២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសតែ គករ ពុំអាចសន្និដ្ឋានថា បោះគាំទ្រគណបក្សនយោបាយណាមួយ ....... ៣៩

ខ-៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ ដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ....... ៣៩

ខ-៤ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច ....... ៤០

ខ-៥ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ....... ៤០

ឧទាហរណ៍

ក- គំរូសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ព ....... ៤០

ខ- គំរូសន្លឹកឆ្នោតមិនបានការត្រូវចាត់ទុកជាមោឃៈ ....... ៤១

ខ-១ សន្លឹកឆ្នោតមិនផ្លូវការ ....... ៤១

ខ-២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសតែ គករ ពុំអាចសន្និដ្ឋានថា បោះគាំទ្រគណបក្សនយោបាយណាមួយ ....... ៤៣

ខ-៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ ដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ....... ៤៤

ខ-៤ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច ....... ៤៥

ខ-៥ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ....... ៤៦

៤- កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ....... ៤៧

ក- ការរៀបចំសម្ភារ ឯកសារ ....... ៤៧

ខ- ការពិនិត្យហិបឆ្នោត ( ចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍) ....... ៤៨

គ- ការរាប់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត ....... ៤៨

ឃ - ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត ....... ៤៩

ង- ការកំណត់សុពលភាព និងការប្រកាសសន្លឹកឆ្នោតដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ....... ៤៩

ច- ការកំណត់សុពលភាពចុងក្រោយនូវរាល់សន្លឹកឆ្នោតមិនបានការ ....... ៥១

៥- ការបូកសរុបលទ្ធផល ការផ្ទៀងផ្ទាត់ និងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោត ....... ៥១

ក- ការបូកសរុបលទ្ធផល ....... ៥១

ខ- រូបមន្តនៃការផ្ទៀងផ្ទាត់ ....... ៥២

៦- ការប្រើប្រាស់ ទ.១១០២ ទ.១១០៨ ទ.១១០៤ ទ.១១២០ និងការវេចខ្ចប់សម្ភារ ឯកសារ ....... ៥៣

ក- ការប្រើប្រាស់ ទ.១១០២ ទ.១១០៨ ទ.១១០៤ ទ.១១២០ ..... ៥៣
ខ- ការវេចខ្ចប់ស្បោងប្លាស្ទិក ..... ៥៤
**VII. ការរៀបចំវេចខ្ចប់ និងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត** ..... ៥៥
១- ការវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ..... ៥៥
២- ការវេចខ្ចប់កញ្ចប់ " ខ " ..... ៥៦
៣- ការវេចខ្ចប់សម្ភារ ឯកសារនៅសល់ ដើម្បីបញ្ជូនទៅ គឃ/សប អមជាមួយកញ្ចប់ " ខ " ..... ៥៨
៤- ការបញ្ជូនកញ្ចប់ " ខ " និងកញ្ចប់ដាក់សម្ភារនៅសល់ទៅ គឃ/សប ក្នុងពេលល្ងាច ឬយប់ ..... ៥៨
៥- ការបញ្ជូនកញ្ចប់ " ខ " និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ នៅព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ..... ៥៨
៦- ការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ/សប ឬនៅទីតាំងសុវត្ថិភាពដែល គ.ជ.ប បានកំណត់ ..... ៥៨

**ទម្រង់បែបបទ** ..... ៦០

# អក្សរកាត់

| | | |
|---|---|---|
| - គ.ជ.ប | : | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| - គធ/ខប | : | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត |
| - គឃ/សប | : | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត |
| - គកប | : | គណៈកម្មការការិយាល័យបោះឆ្នោត |
| - គករ | : | គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត |
| - គកប/គករ | : | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត |
| - ច.ប.ត.រ | : | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ |
| - ប.ន.ត.រ | : | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ |
| - ទ. | : | ទម្រង់បែបបទលេខ |

# គោលបំណង

ក្នុងគោលបំណងឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ នាថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រព្រឹត្តទៅរលូនល្អ ត្រឹមត្រូវ តាម ច.ប.ត.រ និង ប.ន.ត.រ គ.ជ.ប បានរៀបចំចងក្រង " សៀវភៅណែនាំ គកប/គករ " ដើម្បីណែនាំដល់មន្ត្រីពាក់ព័ន្ធនឹងការងារនេះ ឱ្យអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

សៀវភៅណែនាំនេះ ជាសេចក្តីពន្យល់អំពីបច្ចេកទេស បទប្បញ្ញត្តិ និងគោលការណ៍លើចំណុចសំខាន់ៗនៃកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការវេចខ្ចប់ និងការបញ្ជូននូវរាល់សម្ភារ ឯកសារបោះឆ្នោតតាមលំដាប់លំដោយនៃការងារ ។

គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គកប/គករ) ត្រូវយកចិត្តទុកដាក់សិក្សាស្វែងយល់តាមខ្លឹមសារនៃសៀវភៅណែនាំនេះ ដើម្បីតម្រង់ទិសដៅ និងជំរុញការអនុវត្តបច្ចេកទេសជាក់ស្តែងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងសម្រេចបានជោគជ័យ ។

សៀវភៅណែនាំនេះ ក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោត ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទីភារកិច្ចរៀងខ្លួននៅក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឱ្យប្រកបទៅដោយភាពសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព ។

# I. ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ទីតាំងការិយាល័យបោះឆ្នោត នៅតាមភូមិនានាក្នុងឃុំ សង្កាត់ ដែលត្រូវបានកំណត់ និងផ្តល់សុពលភាពជាការិយាល័យបោះឆ្នោតផ្លូវការរួចរាល់ហើយដោយ គ.ជ.ប នឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

ការិយាល័យបោះឆ្នោតត្រូវរៀបចំឱ្យមានច្រកចេញមួយ ច្រកចូលមួយ មានបរិវេណខាងក្នុង បរិវេណខាងក្រៅ និងមានភ្នាក់ងារសន្តិសុខបោះឆ្នោត ។

គ.ជ.ប នឹងផ្តល់ជូន គឃ/សប នូវបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត សម្រាប់បិទផ្សាយពីរ (២) លើក និងរក្សាទុកមួយ (១) ច្បាប់ ជាឯកសារនៅ គឃ/សប ។

**១- ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ក- ការបិទផ្សាយលើកទី ១** : បិទផ្សាយមួយ (១) ច្បាប់ នៅទីស្នាក់ការ គឃ/សប យ៉ាងតិចមួយ (១) ថ្ងៃ មុនថ្ងៃ ចាប់ផ្តើមការឃោសនាបោះឆ្នោត ។

**ខ- ការបិទផ្សាយលើកទី ២** : បិទផ្សាយនៅមួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត

២ច្បាប់
- ១ច្បាប់ បិទនៅទីស្នាក់ការ គឃ/សប
- ១ច្បាប់ ប្រគល់ឱ្យ គកប បិទនៅតាមការិយាល័យបោះឆ្នោត រួមនឹងលេខកូដការិយាល័យបោះឆ្នោត

**គ-** រក្សាទុកជាឯកសារ គឃ/សប ចំនួនមួយ (១) ច្បាប់ ។

**២- បរិវេណខាងក្នុង**

ជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអគារដែលការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាំងនៅហើយ ដែលខណ្ឌដោយវិណ្ឌមណ្ឌលមួយមានកាំប្រវែងយ៉ាងតិចដប់ប្រាំ (១៥) ម៉ែត្រ ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយ ច្រកចូលមួយ ។

**៣- បរិវេណខាងក្រៅ**

ជាតំបន់ព័ទ្ធជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលខណ្ឌដោយវិណ្ឌមណ្ឌលមានកាំប្រវែងមួយរយ (១០០) ម៉ែត្រ ឬមានកាំតូចជាង ស្របតាមស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជារបងវត្តអារាម សាលារៀន សាល ឬទីធ្លាសាធារណៈជាដើម ។

នៅទីប្រជុំជន បរិវេណខាងក្រៅត្រូវបានកំណត់ដោយ គឃ/សប ដោយយោងលើការវាយតម្លៃអំពីស្ថានភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងតំបន់នោះ ។

នៅទីប្រជុំជនណាដែលមានបញ្ហាអសន្តិសុខ ឬ/និងខ្វះសណ្តាប់ធ្នាប់ដែលអាចរំខានដល់ដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត គឃ/សប ត្រូវបង្កើតបរិវេណសន្តិសុខនៅបរិវេណខាងក្រៅទាំងមូល ឬផ្នែកណាមួយនៃបរិវេណខាងក្រៅនោះ ។

### ៤- ភ្នាក់ងារសន្តិសុខបោះឆ្នោត

នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួនបី (៣) នាក់ ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខ នៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិ ឬកងរាជអាវុធហត្ថ ឬកងយោធពលខេមរភូមិន្ទ ឱ្យបានត្រឹមត្រូវ និងមានពាក់បានដៃសន្តិសុខរបស់ គ.ជ.ប រហូតដល់ចប់ភារកិច្ច ។

ភ្នាក់ងារសន្តិសុខបោះឆ្នោតបី (៣) នាក់មានភារកិច្ចការពារកុំឱ្យមានការរំខាន ការអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬហេតុការណ៍ផ្សេងៗដែលនឹងអាចកើតមាន ការពារ និងហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬសារធាតុផ្ទុះ និងវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងនោះ ៖

- ភ្នាក់ងារសន្តិសុខបោះឆ្នោតមួយ (១) នាក់ចល័តការពារជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬក៏ចល័តការពារនៅក្នុង បរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដោយត្រូវស្ថិតនៅក្នុងចម្ងាយពី ១៥ ទៅ ១០០ ម៉ែត្រ ដោយគ្មានសិទ្ធិប្រើប្រាស់អាវុធឡើយ ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោតពីរ (២) នាក់ទៀតចល័តជុំវិញបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលស្ថិតក្នុងចម្ងាយ ពី ១០០ ទៅ ១៥០ ម៉ែត្រ ហើយមានសិទ្ធិប្រើប្រាស់អាវុធវែងមួយ (១) ដើម បង់គ្រាប់ មួយ (១) ដែលមានគ្រាប់យ៉ាងច្រើនសាមសិប (៣០) គ្រាប់ ។

**ចំណាំ** - ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ និងក្រុមពន្លត់អគ្គិភ័យ ) អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ/ខប ប្រធាន គឃ/សប ឬប្រធាន គកប/គករ ។

### ៥- វិធានការសន្តិសុខ

ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត អ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងការិយាល័យបោះឆ្នោត **គ.ជ.ប** គធ/ខប គឃ/សប ឬ/និងប្រធាន គកប/គករ ត្រូវចាត់វិធានការចាំបាច់ ដូចខាងក្រោម ៖

#### ក- វិធានការសម្រាប់ការិយាល័យបោះឆ្នោត

- ហាមជនគ្រប់រូបយកអាវុធជាតិផ្ទុះ ឬសារធាតុ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត ។

- ហាមនាយ ឬពលនៃកងកម្លាំងនគរបាលជាតិ ឬកងយោធពលខេមរភូមិន្ទ ឬកងរាជអាវុធហត្ថណាម្នាក់ ចូលក្នុងការិយាល័យបោះឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខ ប្រសិនបើអ្នកទាំងនោះមិនទៅបោះឆ្នោត ។
- ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនពេលចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។
- សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖
  - ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ ។
  - ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោត បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។
  - ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ ។
- អនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយខាងក្រោម ៖
  - មន្ត្រីបោះឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប ។
  - តំណាងគណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងដែលបានអនុញ្ញាត ។
  - អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ ផ្តល់ឱ្យដោយ គ.ជ.ប ។
  - អ្នកយកព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។
  - អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។
  - នីតិជនអមដំណើរអ្នកបោះឆ្នោតដែលជាជនពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន ។
  - ភ្នាក់ងារសន្តិសុខ ភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានការិយាល័យបោះឆ្នោតមានសំណូមពរក្នុងករណីចាំបាច់ ។

**ខ- វិធានការសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោត**

- ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត ឬក្រោយពេលរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។
- សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង បរិវេណខាងក្រៅ ៖
  - ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ ។
  - ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោត ប្រតិបត្តិដំណើរការរាប់សន្លឹកឆ្នោត បំពេញចិត្ត ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ ។

- អនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងនូវ ៖
    - មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប ។
    - តំណាងគណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងដែលត្រូវបានអនុញ្ញាត អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។
    - ភ្នាក់ងារសន្តិសុខ ភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធានការិយាល័យរាប់សន្លឹកឆ្នោត សំណូមពរក្នុងករណីចាំបាច់ ។

**ចំណាំ** ៖ - ក្នុងករណីចាំបាច់ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវហាមជនគ្រប់រូបចូលក្នុងបរិវេណខាងក្រៅទាំងមូល ឬផ្នែកណាមួយនៃបរិវេណខាងក្រៅនេះ ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

- ជនគ្រប់រូបដែលស្ថិតនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គកប/គករ ។
- ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោត នៅការិយាល័យរបស់ខ្លួនបានដោយករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យនោះ នៅកន្លែងផ្សេងទៀត ។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្តីសម្រេចនេះ ។

## II. គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គកប/គករ )

### ១- សមាសភាព គកប/គករ

សមាសភាព គកប/គករ មានចំនួនប្រាំមួយ (៦) រូប គឺ ប្រធានមួយ (១) រូប អនុប្រធានមួយ (១) រូប លេខាធិការមួយ (១) រូប ជំនួយការពីរ (២) រូប និងសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់មួយ (១) រូប ។ សមាជិក គកប/គករ ទាំងអស់ ត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងម្ចាស់ការអនុវត្តរាល់នីតិវិធីនៃដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

### ២- ការទទួលខុសត្រូវ និងភារកិច្ចរបស់ គកប/គករ

គកប/គករ នីមួយៗមានភារកិច្ចចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតដែល គកប/គករ នោះទទួលខុសត្រូវ ។

ការទទួលខុសត្រូវ និងភារកិច្ចរបស់សមាជិក គកប/គករ ទាំងអស់មានលំអិតស្រាប់នៅក្នុងសកម្មភាពជាក់ស្តែងនៃដំណាក់កាលនីមួយៗ ។

## III. ការត្រួតពិនិត្យវត្តមានសមាសភាព គកប/គករ សម្ភារ ឯកសារ និងទីតាំងការិយាល័យបោះឆ្នោត

គ.ជ.ប ត្រូវធានាថារាល់សម្ភារ ឯកសារបោះឆ្នោតត្រូវបានបញ្ជូននិងប្រគល់ជូន គកប/គករ មិនឱ្យលើសពីសាមសិបប្រាំមួយ (៣៦) ម៉ោង មុនថ្ងៃបោះឆ្នោត ។

មុនថ្ងៃបោះឆ្នោតមួយថ្ងៃ (ថ្ងៃសៅរ៍) ប្រធាន គកប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គកប/គករ ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីត្រួតពិនិត្យវត្តមានសមាសភាព គកប/គករ សម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត និងទីតាំងការិយាល័យបោះឆ្នោត ។

**១- ការត្រួតពិនិត្យវត្តមាន គកប/គករ**

ប្រធាន គកប/គករ ត្រូវត្រួតពិនិត្យវត្តមានសមាសភាព គកប/គករ ដើម្បី ៖

- ឱ្យដឹងថាតើសមាជិក គកប/គករ មានវត្តមានគ្រប់ទាំងប្រាំមួយ (៦)រូប ឬទេ ឬមានសមាជិកណាមួយ ឬច្រើនមិនអាចមកបំពេញការងារបាននៅថ្ងៃបោះឆ្នោត ។
- ចាត់តាំងសមាជិកឱ្យទទួលខុសត្រូវក្នុងការរៀបចំសម្ភារ ឯកសារបោះឆ្នោតតាមតួនាទីរៀងៗខ្លួន។
- ឱ្យសមាជិកម្នាក់ៗរំលឹកឡើងវិញអំពីតួនាទី ភារកិច្ចដែលត្រូវបំពេញនៅថ្ងៃបោះឆ្នោត និងដែលមានចែងក្នុងសៀវភៅណែនាំ ។

**ចំណាំ** ៖ - ប្រសិនបើសមាសភាពណាម្នាក់នៃ គកប/គករ មិនអាចមកបំពេញការងារបានក្នុងថ្ងៃបោះឆ្នោត ប្រធាន ត្រូវតែជូនដំណឹងដល់ គឃ/សប ជាបន្ទាន់ដើម្បីដាក់អ្នកជំនួស។

- បើប្រធានមិនអាចមកបំពេញការងារបានដោយសារមូលហេតុណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ហើយជំនួយការទី១ ចូលកាន់តំណែងអនុប្រធាន ជំនួយការទី២ ចូលកាន់តំណែងជំនួយការទី១ ចំណែកអ្នកជ្រើសរើសថ្មីចូលកាន់តំណែងជំនួយការទី២ ។
- បើអនុប្រធានមិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងជំនួយការទី១ ជាអនុប្រធាន ជំនួយការទី២ ត្រូវជំនួសតំណែងជំនួយការទី១ ហើយអ្នកជ្រើសរើសថ្មីចូលកាន់តំណែងជំនួយការទី២។
- បើលេខាធិការមិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងជំនួយការទី១ ជាលេខាធិការ ជំនួយការទី២ ត្រូវជំនួសតំណែងជំនួយការទី១ ហើយអ្នកជ្រើសរើសថ្មីត្រូវ ចូលកាន់តំណែងជំនួយការទី២ ។

- ប្រសិនបើ គឃ/សប មិនអាចជូនដំណឹងអំពីការដាក់អ្នកជំនួសទាន់ពេលវេលា ដោយសារតែចម្ងាយផ្លូវឬដោយសារតែកង្វះខាតនៃមធ្យោបាយធ្វើដំណើរ គកប/គករ ត្រូវជ្រើសរើសមនុស្សដែលមានលក្ខណសម្បត្តិសមស្របតាមច្បាប់កំណត់ឱ្យមកធ្វើការជំនួសតំណែងក្នុង គកប/គករ ដែលអវត្តមាន។ ប្រធាន គកប/គករ ត្រូវជូនដំណឹងជាបន្ទាន់ដល់ គឃ/សប អំពីការដាក់ជំនួសនោះ ។

- សមាជិកថ្មីនៃ គកប/គករ ត្រូវតែបានបណ្តុះបណ្តាល ដោយសិក្សារួមគ្នាជាមួយសមាជិកទាំងអស់នូវនីតិវិធីនៃការបោះឆ្នោត និងសៀវភៅណែនាំរបស់ គ.ជ.ប ឡើងវិញ នៅមួយ (១) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

**២- ការទទួល និងការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ក- សម្ភារ ឯកសារបោះឆ្នោតដែល គកប/គករ ត្រូវទទួល ៖**

- បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធចំនួនពីរ (២) ច្បាប់ ។
- សន្លឹកឆ្នោតមួយ (១) កញ្ចប់ ដែលត្រូវបានវេចខ្ចប់ដោយឡែក និងអមដោយត្រាសម្ងាត់មួយ (១) សម្រាប់បោះលើខ្នងសន្លឹកឆ្នោតដែលដាក់ក្នុងស្រោមសំបុត្របិទជិតសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។
- ហិបឆ្នោតមួយ (១) ដែលមិនទាន់ដំឡើង និងវេចខ្ចប់ដោយឡែក ។
- បន្ទប់សម្ងាត់ស័ង្កសីបីផ្នត់ សម្រាប់គូសសន្លឹកឆ្នោតចំនួនពីរ (២) ដែលមិនទាន់ដំឡើង និងវេចខ្ចប់ច្រកក្នុងការុងនីឡុងមួយដោយឡែក និងអមដោយស្កុតមួយ (១) ដុំផង ។
- ទឹកខ្មៅលុបលាងមិនជ្រះចំនួនពីរ (២) ដប ។
- រាល់សម្ភារ ឯកសារបម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ដែលត្រូវបានដាក់ក្នុងកេសស័ង្កសីមួយ ។ សម្ភារទាំងនោះរួមមាន ៖
  - ស្លាកសម្គាល់ "ការិយាល័យបោះឆ្នោត" បោះពុម្ពលើកំណាត់ប្លាស្ទិក ចំនួនមួយ (១) ។
  - បណ្ណប្រកាសហាមប្រើប្រាស់ទូរស័ព្ទដៃ ម៉ាស៊ីន និងឧបករណ៍ថតរូប ចំនួនពីរ (២) សន្លឹក ។
  - ត្រាការិយាល័យបោះឆ្នោត ចំនួនមួយ (១) ។
  - តាំប៉ុងពណ៌ក្រហម ចំនួនមួយ (១) ប្រអប់ និងទឹកតាំប៉ុងក្រហម ចំនួនមួយ(១)ដប ។
  - ប៊ិចមានខ្សែចងសម្រាប់គូសសន្លឹកឆ្នោត និងប៊ិចធម្មតាសម្រាប់ គកប/គករ សរុបទាំងពីរមុខចំនួន ប្រាំបី (៨) ដើម ។
  - ប៊ិចហ្វឺតធំលុបមិនជ្រះ ចំនួនមួយ (១) ដើម ។
  - ប៊ិចហ្វឺតធំ ចំនួនមួយ(១)ដើម ។
  - បន្ទាត់ជ័រ ចំនួនមួយ (១) ដើម ។
  - ជ័រការវ៉ាវ ចំនួនមួយ (១)ដប ។
  - កៅស៊ូកង មួយចំនួនសម្រាប់ចងសន្លឹកឆ្នោតតាមគណបក្ស ។
  - ស្រោមសំបុត្រធំចំនួនមួយ (១) មធ្យមចំនួនប្រាំបួន (៩) និងតូចចំនួនពីរ (២) ។
  - ក្រដាសស្តើងសម្រាប់បិទពាសសន្ទះបិទប្រឡោះស៊កសន្លឹកឆ្នោត ចំនួនប្រាំមួយ (៦) សន្លឹក ។
  - ក្រដាសរ៉ាមសម្រាប់ប្រើប្រាស់ការងារផ្សេងៗ ចំនួនម្ភៃ (២០) សន្លឹក ។
  - ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ចំនួនពីរ (២) ផ្ទាំង ។

- ផ្ទាំងក្រដាសធំសម្រាប់កត់ត្រាសំឡេងឆ្នោត ចំនួនមួយ (១) សន្លឹក ។
- ក្របក្រដាសពិសេសមានចោះប្រហោង សម្រាប់ជនពិការភ្នែកទាំងសងខាងដែលមានបំណងបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។
- ទ.១១០១ ចំនួនប្រាំមួយ (៦) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត ។
- ទ.១១០២ ចំនួនប្រាំមួយ (៦) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។
- ទ.១១០៤ សម្រាប់ចម្លងលទ្ធផលបឋមនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត ចំនួនម្ភៃ (២០) សន្លឹក ។
- ទ.១១០៧ ចំនួនប្រាំមួយ (៦) ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូន និង ប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ។
- ទ.១១០៨ ចំនួនបួន (៤) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោត ។
- ទ.១១១២ ចំនួនបួន (៤) ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតដែល គកប/គករ បានទទួល ។
- ទ.១១១៥ សម្រាប់ស្រង់វត្តមានតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោត ។
- ទ.១១២០ សម្រាប់ស្រង់វត្តមានអ្នកសង្កេតការណ៍ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ទ.១២០២ ចំនួនពីរ (២) ក្បាល ក្នុងមួយក្បាលមានម្ភៃ (២០) ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។
- ស្បោងប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតដែលមិនបានប្រើ និងគល់សន្លឹកឆ្នោតដែលប្រើហើយចំនួនមួយ (១) ។
- ស្បោងប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ចំនួនមួយ (១) ។
- កញ្ចប់សុវត្ថិភាព "ក" សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោត ចំនួនមួយ (១) ។
- កញ្ចប់ "ខ" សម្រាប់ដាក់កញ្ចប់សុវត្ថិភាព "ក" និងសម្ភារ ឯកសារបោះឆ្នោតចំនួនមួយ(១) ។
- សោឃ្លុំជ័រមានលេខសម្រាប់ចាក់ភ្ជាប់គម្របខាងក្នុង និងខាងក្រៅនៃហិបឆ្នោត ចំនួនបី (៣) ។
- សោឃ្លុំជ័រមានលេខសម្រាប់ឃ្លុំបិទមាត់កញ្ចប់ "ខ" ចំនួនមួយ (១) ។
- ប្រដាប់ចោះសន្លឹកឆ្នោតចំនួនមួយ(១) ។

**ខ- ការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត**

គកប ត្រូវត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែល គកប បានទទួល ហើយដែលមានរាយមុខនៅក្នុង ទ.១១០៧ ក្នុងនោះត្រូវ ៖

- ត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោតដោយប្រើតារាងត្រួតពិនិត្យទ.១១១២ ហើយសមាសភាពទាំងអស់នៃ គកប ត្រូវចុះហត្ថលេខាលើ ទ.១១១២ និងរក្សាទុកឱ្យបាន ហ្មត់ចត់ ។
- ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតណាមួយឬច្រើន ដែលបានទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់នៅក្នុង ទ.១១១២ ហើយ ផ្ញើ ទ.១១១២ នេះ ចំនួនមួយ (១) ច្បាប់ ជាបន្ទាន់ទៅ គឃ/សប ។ ប្រសិនបើសម្ភារដែល មិនបានទទួលនោះជាសម្ភារសំខាន់សម្រាប់ការបោះឆ្នោត ប្រធាន គកប ត្រូវចាត់សមាជិកពីរ (២) រូប ទៅកាន់ទីស្នាក់ការ គឃ/សប ដើម្បីទទួលសម្ភារថ្មីជំនួសសម្ភារដែលខ្វះ ឬទាក់ទង តាមទូរស័ព្ទ ឬវិទ្យុទាក់ទងស្នើសុំ គឃ/សប ដោះស្រាយ ។
- គកប ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យសម្ភារសំខាន់ៗដែលអាចរាំងស្ទះដល់ការបើកការិយាល័យ បោះឆ្នោត ។ សម្ភារសំខាន់ៗទាំងនោះរួមមាន ៖
    - សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។
    - ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។
    - បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។
    - ហិបឆ្នោត និងសោឃ្លុំមានលេខ ។
    - ទឹកខ្មៅលុបលាងមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃ ។
- ចំពោះសម្ភារដទៃទៀត ប្រសិនបើមិនបានផ្តល់ដោយ គឃ/សប ទេនោះ គកប ត្រូវច្នៃ បង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ដូចជា ៖
    - បន្ទប់សម្ងាត់ ត្រូវជំនួសដោយកន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាច ប្រើបិទបាំងជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។
    - ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃដែលអាចជំនួសទម្រង់បែបបទសម្រាប់បំពេញ កំណត់ហេតុគំរូ ។
    - ប៊ិចសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង....... ។

**ចំណាំ** ៖ _ ចំពោះកញ្ចប់សន្លឹកឆ្នោត គ្រាន់តែពិនិត្យឱ្យប្រាកដថាជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យនោះ ហើយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតតែប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតដាច់ខាត ។

- ចំពោះត្រាសម្ងាត់ គ្រាន់តែពិនិត្យស្រោមសំបុត្រដើម្បីឱ្យដឹងថា មានត្រានៅខាងក្នុងតែប៉ុណ្ណោះ ដោយមិនត្រូវបើកស្រោមសំបុត្រដាច់ខាត ។

**គ- ក្រោយការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (នៅថ្ងៃសៅរ៍ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត)**

**ប្រធាន គកប ត្រូវ**

- ចាត់ជំនួយការទី២ ឱ្យបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតផ្លូវការមួយ (១) ច្បាប់នៅមុខការិយាល័យបោះឆ្នោត ។
- បិទស្លាក និងលេខកូដការិយាល័យបោះឆ្នោតនៅលើច្រកទ្វារការិយាល័យបោះឆ្នោត ។
- ចាត់ចែងសមាជិកឱ្យហាត់ដំឡើងហិបឆ្នោត និងបន្ទប់សម្ងាត់ ។

**ឃ- ការរក្សាការពារសម្ភារ ឯកសារបោះឆ្នោត**

**ប្រធាន គកប ត្រូវ**

- រក្សាទុកនៅផ្ទះប្រធាន ឬផ្ទះសមាជិកណាម្នាក់ ឬនៅទីណាមួយមានសុវត្ថិភាព និងត្រូវបានឯកភាពពី គកប និងជូនដំណឹងដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។
- ចាត់ចែងឱ្យមានអ្នកការពារយ៉ាងហោចណាស់ក៏មានសមាជិក ៣ រូប ដែលគិតទាំងប្រធានផង ។
- ស្នើសុំកម្លាំងសន្តិសុខការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលរក្សាទុកសម្ភារឯកសារបោះឆ្នោត ។

**៣- ការពិនិត្យទីតាំងការិយាល័យបោះឆ្នោត**

ប្រធាន គកប ត្រូវពិនិត្យ និងរៀបចំទីតាំងការិយាល័យបោះឆ្នោត ឱ្យបានរួចរាល់ជាស្រេច នៅថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត ដើម្បីត្រៀមសម្រាប់សមាជិកម្នាក់ៗនៃ គកប រៀបចំសម្ភារ ឯកសារបោះឆ្នោត ទៅតាមកន្លែងរៀងៗខ្លួនឱ្យរួចស្រេចនៅម៉ោងប្រាំមួយ (៦:០០) ព្រឹកនៃថ្ងៃបោះឆ្នោត ។ ប្រធាន គកប ត្រូវចាត់ចែង ៖

- បោសសំអាតការិយាល័យ ។
- រៀបចំគំរូប្លង់ការិយាល័យបោះឆ្នោតតាមការកំណត់ដែលមានស្រាប់នៅក្នុងសៀវភៅណែនាំនេះ ។
- រៀបចំតុ កៅអី និងសម្ភារដទៃទៀតឱ្យមានចំនួនគ្រប់គ្រាន់ សម្រាប់ដំណើរការបោះឆ្នោត បើគ្មាន ឬមានចំនួនមិនគ្រប់គ្រាន់ ប្រធានត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់ ដើម្បីជួយសម្រួលដល់ការងារបោះឆ្នោត ។
- រៀបចំបន្ទប់ឱ្យមានច្រកចេញមួយ និងច្រកចូលមួយ ។ ច្រកចេញចូល និងបន្ទប់សម្ងាត់ត្រូវរៀបចំឱ្យមានទំហំធំល្មមដែលអាចឱ្យរទេះជនពិការងាយចេញចូលបោះឆ្នោតបាន ។

- បិទបង្អួចចាក់សោទ្វារ ( ប្រសិនបើមានសោ) និងស្នើសុំកម្លាំងសន្តិសុខយាមការពារ ។
- ណាត់សមាជិកទាំងអស់ឱ្យមកកាន់ទីកន្លែងរក្សាទុកសម្ភារ ឯកសារបោះឆ្នោត នៅម៉ោងប្រាំសាមសិបនាទី (៥:៣០) ព្រឹកនៃថ្ងៃបោះឆ្នោត ដើម្បីជួយដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។
- ជម្រាបសមាជិកទាំងអស់ ឱ្យត្រៀមអាហារសម្រាប់រយៈពេល ១ថ្ងៃ សម្រាប់ហូបនៅពេលទំនេរដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប ។




**៤- ការប្រើប្រាស់បញ្ជីបោះឆ្នោត**

បញ្ជីបោះឆ្នោតសម្រាប់ គកប ២ច្បាប់
- ១ ច្បាប់ បិទនៅមុខការិយាល័យបោះឆ្នោតនៅ ថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត
- ១ ច្បាប់ ទុកប្រើប្រាស់នៅថ្ងៃបោះឆ្នោត ។

**សម្គាល់** ៖ គឃ/សប ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតនៅទីស្នាក់ការ គឃ/សប ១ ច្បាប់ ១ ខែមុនថ្ងៃបោះឆ្នោត ។

## IV. ការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅថ្ងៃបោះឆ្នោត

សមាសភាព គកប ទាំងអស់ ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត នៅម៉ោងប្រាំមួយ (៦:០០) ព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដោយនាំសម្ភារ ឯកសារបោះឆ្នោតមកជាមួយផង ។

ប្រធាន គកប ត្រូវ ៖

- ប្រកាសអញ្ជើញតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិចូលក្នុងការិយាល័យបោះឆ្នោតដោយត្រូវពិនិត្យស្លាកសម្គាល់ ឬសេចក្តីសម្រេចតែងតាំងនិងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ និងប្រាប់ទីកន្លែងដែលបានបម្រុងទុកជូន ។
- ចាត់ចែងសមាជិក គកប ឱ្យរៀបចំគ្រឿងសង្ហារិម សម្ភារ ឯកសារបោះឆ្នោត តាមតួនាទី ភារកិច្ច និងតាមទីកន្លែងរៀងៗខ្លួនតាមគំរូប្លង់ដូចបានឯកភាពគ្នានៅមុនថ្ងៃបោះឆ្នោត ។
- ចាត់ចែង និងណែនាំជំនួយការទី២ ឱ្យបំពេញការងាររបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ( មើលភារកិច្ចរបស់ជំនួយការទី២ ទៅទំព័រទី១៩ ) ។

**ចំណាំ ៖**

- ឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចុះវត្តមានក្នុង ទ.១១០១
- ឱ្យអ្នកសង្កេតការណ៍ចុះវត្តមាន ក្នុងបញ្ជីវត្តមានអ្នកសង្កេតការណ៍ ( ទ.១១២០ ) ។

**១- ការរៀបចំសម្ភារ ឯកសារបោះឆ្នោត និងការពន្យល់ណែនាំដល់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍**

**ក- ការរៀបចំសម្ភារតាមគំរូប្លង់**

- តុមួយនៅខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូល សម្រាប់ប្រធាន ។

**កន្លែងប្រធានមាន** ⇨

- ទ.១២០២ ( ពាក្យបណ្តឹង) ។
- ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានសម្ភារ ឯកសារមិនទាន់ប្រើប្រាស់ ត្រូវដាក់នៅក្បែរតុប្រធាន ។
- ទ.១១២០ សម្រាប់ចុះវត្តមានអ្នកសង្កេតការណ៍ ។
- ក្របក្រដាសពិសេសសម្រាប់អ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាង ។

- តុវែងមួយ ឬខ្លីពីរ (២) ដាក់ជាប់គ្នានៅខាងស្តាំដៃបន្ទាប់ពីផ្លូវចូល សម្រាប់លេខាធិការ និងអនុប្រធាន អង្គុយជាប់គ្នា ។

**កន្លែងលេខាធិការមាន** ⇨

- បញ្ជីបោះឆ្នោតមួយ ( ១ ) ច្បាប់ ។
- កំណត់ហេតុនៃការបោះឆ្នោត ( ទ.១១០១) ចំនួនបី ( ៣)ច្បាប់) ។
- ទម្រង់បែបបទផ្សេងៗទៀត ។

**កន្លែងអនុប្រធានមាន** ⇨

- កញ្ចប់សន្លឹកឆ្នោត ។
- ស្រោមសំបុត្រដាក់ត្រាសម្ងាត់ និងតាំប៉ុងពណ៌ក្រហម ។

- តុពីរ(២)សម្រាប់ដាក់ទូបន្ទប់សម្ងាត់ពីរ (២) ដោយត្រូវមានចម្ងាយពីគ្នាយ៉ាងតិចមួយ (១)ម៉ែត្រ ឃ្លាតពីជញ្ជាំងប្រវែងមួយ (១) ម៉ែត្រទៅមួយម៉ែត្រកន្លះ (១,៥០ម) (មិនអនុញ្ញាតឱ្យដាក់ក្បែរបង្អួច) ។

| | |
|---|---|
| **បន្ទប់សម្ងាត់ពីរក្នុងបន្ទប់នីមួយៗមាន** | - ប៊ិចមួយ (១) ដើមចងខ្សែភ្ជាប់ស្រាប់ ។<br>- ផ្ទាំងក្រដាសមួយ (១) សន្លឹក សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត និងត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់នីមួយៗ ។ |

- តុវែងមួយ(១)សម្រាប់ជំនួយការទី១ ដាក់នៅកណ្តាលបន្ទប់ទល់មុខតុប្រធាន ។

| | |
|---|---|
| **តុវែង ១ សម្រាប់ជំនួយការទី ១មាន** | - ហិបឆ្នោតដំឡើងរួច ។<br>- ទឹកខ្មៅលុបលាងមិនជ្រះចំនួនពីរ (២) ដប ។<br>- កំណាត់សម្រាប់ជូតម្រាមដៃអ្នកបោះឆ្នោត ។ |

- កៅអី (ប្រសិនបើមាន) ដាក់អែបជញ្ជាំង ខាងឆ្វេងដៃប្រធាន និងដាក់ខាងក្រោយតុអនុប្រធាន និងលេខាធិការ សម្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

**ចំណាំ ៖**

- គកប ត្រូវអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ស្ថិតនៅជិតល្មម ខាងក្រោយអនុប្រធាន និងលេខាធិការដែលអាចមើល ឃើញឯកសារបាន ។
- ការផ្លាស់ប្តូរទីកន្លែងឈរ ឬអង្គុយរបស់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវមានការអនុញ្ញាតពីប្រធាន គកប ។

**ខ- ការពន្យល់ណែនាំដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍**

ទន្ទឹមនឹងពេលរៀបចំសម្ភារ ឯកសារបោះឆ្នោត ប្រធាន គកប ត្រូវណែនាំជារួមដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានាដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ៖

- ត្រូវគោរព ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ និងគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលកំណត់ដោយ គ.ជ.ប ។
- ត្រូវតាមដានជាប្រចាំរាល់កិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតបង្ការក្រែងមានភាពមិនប្រក្រតីកើតឡើង ។
- ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។
- ត្រូវលើកសំណួរ ឬ/និងសំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ ដោយផ្ទាល់ទៅប្រធាន គកប/គករ ។
- មិនត្រូវណែនាំអ្វីដល់សមាសភាព គកប/គករ ។
- មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត ។

- មិនត្រូវធ្វើអ្វីឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ត្រូវបំពេញបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទ.១១២០ ដោយត្រូវបញ្ជាក់ឈ្មោះអង្គការសាមី ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខាផង ។

**២- ភារកិច្ចរបស់ គកប នៅចន្លោះពីម៉ោងប្រាំមួយ (៦:០០) ព្រឹក ដល់ម៉ោងប្រាំមួយសាមសិបនាទី (៦:៣០) ព្រឹក នៃថ្ងៃបោះឆ្នោត**

| ប្រធាន គកប ត្រូវ | |
|---|---|
| | - ជាដំបូងប្រកាសដល់អ្នកបោះឆ្នោត និងអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ហាមប្រើទូរស័ព្ទដៃ ឬ/និងម៉ាស៊ីន ឬ/និងឧបករណ៍ផ្សេងទៀតដែលអាចថតរូបបាន (លើកលែងតែអ្នកយកព័ត៌មានដែលមានពាក់បណ្ណសម្គាល់អ្នកយកព័ត៌មាន ចេញដោយ គ.ជ.ប និងបានទទួលការអនុញ្ញាតពីប្រធាន គកប) ឬ/និងហាមធ្វើសកម្មភាពទាំងឡាយណាដែលរំលោភលើការសម្ងាត់នៃការបោះឆ្នោត ក្នុងការិយាល័យបោះឆ្នោត ។<br>- បន្ទាប់មកត្រូវពិនិត្យឡើងវិញនូវហិបឆ្នោតដើម្បីឱ្យប្រាកដថា បានដំឡើងត្រឹមត្រូវតាមការណែនាំ ។<br>- បើកគម្របក្រៅ គម្របក្នុងនៃហិបឆ្នោត ។<br>- បង្ហាញហិបឆ្នោតទទេ ចំពោះមុខអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកបិទគម្របក្នុងនៃហិបឆ្នោតវិញ រួចមួលភ្ជិតគម្របសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ខ្ទាស់គន្លឹះគម្របក្នុង និងចាក់សោឃ្លុំមានលេខ ។<br>- ចាត់លេខាធិការឱ្យកត់ត្រា លេខសោឃ្លុំនៅលើ ទ.១១០១ ។<br>- យកក្រដាសលេខកូដការិយាល័យបោះឆ្នោតនោះចំនួនពីរ (២)សន្លឹក រួចបោះត្រាការិយាល័យ ។<br>- បិទក្រដាសនោះភ្ជាប់ទៅនឹងជញ្ជាំងមុខក្រោយនៃហិបឆ្នោត ។<br>- អនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោត និងលេខសោឃ្លុំ ។<br>- ចាត់លេខាធិការឱ្យកត់ត្រា ពេលម៉ោងនៃការពិនិត្យហិបឆ្នោតក្នុង ទ.១១០១ ។ |

**ចំណាំ** **ក្នុងពេលបោះឆ្នោត ៖**

- មិនអនុញ្ញាតឱ្យយកហិបឆ្នោតចេញពីការិយាល័យបោះឆ្នោត ។
- មិនអនុញ្ញាតឱ្យបើកហិបឆ្នោតដាច់ខាត ។
- ជំនួយការទី២ នៅខាងក្រៅការិយាល័យបោះឆ្នោតអាចប្រើប្រាស់ទូរស័ព្ទបាន ដើម្បីទាក់ទងការងារ ។




ប្រធាន គកប បង្ហាញហិបឆ្នោតទទេដល់សមាជិក គកប តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍




សោឃុំមានលេខដែលប្រធានចាក់ភ្ជាប់ត្រង់គន្លឹះគម្របក្នុងនៃហិបឆ្នោត

**៣- ភារកិច្ចរបស់ គកប នៅចន្លោះពីម៉ោងប្រាំមួយសាមសិប (៦:៣០) ព្រឹក ដល់ម៉ោងប្រាំពីរ (៧:០០) ព្រឹក នៃថ្ងៃបោះឆ្នោត**

ប្រធាន គកប ត្រូវចាត់ចែងត្រួតពិនិត្យកញ្ចប់សន្លឹកឆ្នោត លេខរៀងសន្លឹកឆ្នោត រាប់ចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្តែង និងពិនិត្យត្រាសម្ងាត់ផ្លូវការ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ។

## ក- ការពិនិត្យកញ្ចប់សន្លឹកឆ្នោត

| | |
|---|---|
| ប្រធាន គកប ត្រូវ | - ចាត់អនុប្រធានពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យដឹងប្រាកដថា មិនត្រូវបានគេរុះរើកញ្ចប់ឡើយ ។<br>- ចាត់អនុប្រធានឱ្យបើកកញ្ចប់សន្លឹកឆ្នោតពិនិត្យមើល និងធានាថា សន្លឹកឆ្នោតដែលទទួលបាននេះជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតរបស់ខ្លួនប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រប្រាកដមែន (បើមិនមែន ប្រធាន គកប ត្រូវរាយការណ៍ជាបន្ទាន់ តាមរយៈ គឃ/សប និង គធ/ខប ជូន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ) ។<br>- បន្ទាប់មក ឱ្យអនុប្រធានរាប់ចំនួនសន្លឹកឆ្នោតដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោត ដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី ៥០ ដល់ ៩៩ សន្លឹក ។<br>- ចាត់លេខាធិការ ឱ្យកត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាក់ស្តែង (ទោះបីចំនួនសន្លឹកឆ្នោត ដែលបានរាប់ឃើញមានចំនួនស្មើនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ឱ្យក្តី ឬមានចំនួនលើស ឬខ្វះក្តី) និងកត់ត្រាលេខរៀងដើមដំបូងបង្អស់ និងចុងក្រោយបង្អស់នៃសន្លឹកឆ្នោតដែលបញ្ជាក់លើគល់បញ្ជីសន្លឹកឆ្នោត ក្នុង ទ.១១០១ ។<br>- បន្ទាប់មកឱ្យលេខាធិការកត់ត្រាចំនួនអ្នកបោះឆ្នោតដែលមាននៅក្នុងបញ្ជីបោះឆ្នោតក្នុង ទ.១១០១ ។ |

## ខ- ការពិនិត្យ និងបង្ហាញត្រាសម្ងាត់

| | |
|---|---|
| ប្រធាន គកប ត្រូវ | - ពិនិត្យ និងបង្ហាញអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ដើម្បីឱ្យដឹងប្រាកដថាស្រោមសំបុត្រដាក់ត្រាសម្ងាត់ មិនត្រូវបានគេរុះរើឡើយ ។<br>- បើកស្រោមសំបុត្រដែលមានត្រាសម្ងាត់ ។<br>- ដកយកត្រាសម្ងាត់បោះសាកល្បងនៅលើក្រដាសពណិស ។<br>- ដាក់បង្ហាញអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោតទាំងអស់ឱ្យបានឃើញច្បាស់ និងចំណាំរូបសញ្ញានៃត្រាសម្ងាត់នោះ ។ |

**ចំណាំ** - ករណីសម្ភារ ឯកសារបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោត ត្រូវបានទទួលនៅក្រោយម៉ោងប្រាំមួយសាមសិបនាទី (៦:៣០) ប៉ុន្តែមិនទាន់ហួសម៉ោងប្រាំពីរ (៧:០០) ព្រឹកនៃថ្ងៃបោះឆ្នោត ៖

| | |
|---|---|
| ប្រធាន គកប ត្រូវ | - ព្យួរការអនុវត្តនីតិវិធីបន្ទាប់នៃការបោះឆ្នោត នៅការិយាល័យនោះជាបណ្ដោះអាសន្នសិន រហូតទាល់តែការពិនិត្យ និងបង្ហាញហិបឆ្នោត ព្រមទាំងការពិនិត្យសន្លឹកឆ្នោត និងត្រាសម្ងាត់ត្រូវបានបំពេញចប់សព្វគ្រប់ ។<br>- ចាត់លេខាធិការកត់ត្រាពេលម៉ោងនៃការពិនិត្យ និងបង្ហាញហិបឆ្នោត និងកត់ត្រាចំនួនសន្លឹកឆ្នោត ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ទៅក្នុង ទ.១១០១ ឱ្យបានច្បាស់លាស់ ។<br>- បើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោងប្រាំពីរ (៧:០០ព្រឹក ) ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោងប្រាំបី (៨:០០) ព្រឹកឡើយ ។ |

**៤- ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការប្រើប្រាស់សម្រាប់ការបោះឆ្នោត គឺឯកសារណាមួយក្នុងចំណោមឯកសារខាងក្រោម ៖**

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ រួមទាំងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហួសសុពលភាព
- អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល
- អត្តសញ្ញាណប័ណ្ណនគរបាលជាតិ
- អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ
- លិខិតឆ្លងដែន
- ឆាយាគណៈមហានិកាយ
- សុទ្ធិបត្រគណៈធម្មយុត្តិកនិកាយ
- សង្ឃដីកា
- បណ្ណសម្គាល់ខ្លួនចេញដោយក្រសួង ស្ថាប័នរដ្ឋ
- សៀវភៅគ្រួសារ ឬបណ្ណសម្គាល់គ្រួសារមានបិទរូបថតសាមីខ្លួន
- លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត (បណ្ណខៀវ ) ។

## អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ



## អត្តសញ្ញាណបណ្ណមន្ត្រីរាជការស៊ីវិល



## អត្តសញ្ញាណបណ្ណនគរបាលជាតិ



## អត្តសញ្ញាណបណ្ណកងយោធពលខេមរភូមិន្ទ



## លិខិតឆ្លងដែន




## អាយាគណៈមហានិកាយ



### សុទ្ធិបត្រគណៈធម្មយុត្តិកនិកាយ




### សង្ឃដីកា




### បណ្ណសម្គាល់ខ្លួនចេញដោយក្រសួង ស្ថាប័នរដ្ឋ




### សៀវភៅគ្រួសារមានបិទរូបថតសាមីខ្លួន




### បណ្ណសំគាល់គ្រួសារមានបិទរូបថតសាមីខ្លួន




### លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត (បណ្ណខៀវ)



### ៥- ពេលបោះឆ្នោតចាប់ពីម៉ោងប្រាំពីរ (៧:០០) ព្រឹក ដល់ម៉ោងបី (៣:០០) រសៀល




ប្រធាន គកប ត្រូវប្រកាសបើកការិយាល័យបោះឆ្នោត នៅម៉ោងប្រាំពីរ (៧:០០) ព្រឹកនៃថ្ងៃបោះឆ្នោត រួចអញ្ជើញសមាសភាព គកប ឱ្យបោះឆ្នោតមុនគេបង្អស់ បន្ទាប់មកតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន ប្រសិនបើអ្នកទាំងនោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។ ប្រធាន គកប ត្រូវចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ។ យ៉ាងយូរមួយ (១) ម៉ោងម្តង ប្រធាន ត្រូវត្រួតពិនិត្យក្នុងបន្ទប់សម្ងាត់ អំពីសុវត្ថិភាពសម្ភារដែលបំពាក់នៅទីនោះ និងសណ្តាប់ធ្នាប់ ក្នុងពេលគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់។ ប្រធានត្រូវតាមដានពិនិត្យមើលដើម្បីឱ្យប្រាកដថា នៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបានបត់សន្លឹកឆ្នោតតាមផ្នត់ដើមដូចការណែនាំ និងចាត់ចែងការងារតាមលំដាប់លំដោយដូចតទៅ ៖

**ជំនួយការទី ២ ត្រូវ**

- ចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង ។
- ជួយរកឈ្មោះ និងលេខរៀងអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ។
- បើក្នុងបណ្ណព័ត៌មានអ្នកបោះឆ្នោតឃើញឈ្មោះ និងទីតាំងការិយាល័យផ្សេង ជម្រាបគាត់ឱ្យទៅកាន់ការិយាល័យបោះឆ្នោតនោះ ដើម្បីបោះឆ្នោត ។
- ចេញក្រដាសលេខរៀងតាមលំដាប់មុនក្រោយ (បើអាចធ្វើបាន)។
- ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តគ្នាជាជួរ ។
- ប្រសិនបើការបោះឆ្នោតឈានដល់ម៉ោងបី (៣:០០) រសៀលនៃថ្ងៃបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតទៀត អ្នកទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត ។ ត្រូវដើរប្រមូលយកឯកសារបញ្ជាក់អត្តសញ្ញាណពីអ្នកបោះឆ្នោតដែលកំពុងឈរក្នុងជួរ ដោយចាប់ផ្តើមពីអ្នកបោះឆ្នោតដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ឱ្យសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់នៅត្រង់មាត់ទ្វារ ។
- ត្រូវបញ្ជូន ទ.១១២០ មក គឃ/សប ស្របពេលនឹងការបញ្ជូនក្រដាសលទ្ធផលបឋម (ទ.១១០៤) ។

**សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ត្រូវ**

- ជម្រាបអ្នកបោះឆ្នោតដែលកំពុងឈរជាជួរបន្តគ្នា នៅក្នុងបរិវេណខាងក្នុងអំពីអ្នកបោះឆ្នោតដែលត្រូវផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត ។
- ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោតមុនគេដល់អ្នកបោះឆ្នោតជាព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ អ្នកមានជំងឺ ជនពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយជានីតិជនអមដំណើរជនពិការនោះ បន្ទាប់មកគឺអ្នកឈរមុខគេក្នុងជួរ ។
- រំលឹកអ្នកបោះឆ្នាត ឱ្យរកមើលឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅមុខទីតាំងការិយាល័យបោះឆ្នោត ៖
  - បើរកឃើញឈ្មោះ ត្រូវឱ្យគាត់ចាំលេខរៀង ដើម្បីជម្រាបជូនលេខាធិការ ។
  - បើរកមិនឃើញឈ្មោះ ត្រូវជម្រាបជូនជំនួយការទី២ ដើម្បីជួយរកឈ្មោះ ។
- ឱ្យអ្នកបោះឆ្នោតបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ ដែលត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោត និងបណ្ណព័ត៌មានអ្នកបោះឆ្នោត (ប្រសិនបើមាន) ។
- ពិនិត្យមើលម្រាមដៃរបស់គាត់ ក្រែងមានស្នាមទឹកខ្មៅលុបលាងមិនជ្រះ (បើមានប្រឡាក់ស្នាមទឹកខ្មៅលុបលាងមិនជ្រះត្រូវនាំគាត់ទៅជួបប្រធាន) ។
- ជម្រាបអ្នកបោះឆ្នោតឱ្យដើរតម្រង់ទៅតុលេខាធិការ និងអនុប្រធានដែលកំពុងអង្គុយ ។
- អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលម្តងម្នាក់ៗ និងរក្សាចំនួនអ្នកបោះឆ្នោតមិនឱ្យលើសពីបួន(៤)នាក់ក្នុងការិយាល័យបោះឆ្នោត ។

# ដំណើរនៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត




អាចឈរពីក្រោយលេខាធិការ និងអនុប្រធាន

**លេខាធិការ ត្រូវ**

- ឱ្យអ្នកបោះឆ្នោតបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយរបស់គាត់ រួមជាមួយបណ្ណព័ត៌មានអ្នកបោះឆ្នោត ( ប្រសិនបើមាន) ឬសួរគាត់ពីលេខរៀងឈ្មោះ ។
- ត្រួតពិនិត្យម្រាមដៃរបស់គាត់ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបលាងមិនជ្រះ ។
- រកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតតាមលេខរៀងក្នុងបណ្ណព័ត៌មានអ្នកបោះឆ្នោត ( ប្រសិនបើមាន) រួចប្រគល់បណ្ណព័ត៌មានជូនគាត់វិញ ។
- ពិនិត្យផ្ទៀងផ្ទាត់ រូបថតដែលបិទលើឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ជាមួយនឹងរូបពិត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត ។
- ដាក់បន្ទាត់តម្រង់តាមបណ្តោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាមួយបញ្ជាក់ការមកបោះឆ្នោតរបស់គាត់ ក្នុងកូនប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ ។
- ហុចឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់បន្តទៅឱ្យអនុប្រធាន ។
- ជម្រាបគាត់ឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន ។




**លេខាធិការពិនិត្យរកមើលស្នាមទឹកខ្មៅលុបលាងមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត**

**ចំណាំ** ៖ – បើពិនិត្យឃើញថា ម្រាមដៃគាត់មានស្នាមទឹកខ្មៅលុបលាងមិនជ្រះ ត្រូវជូនគាត់ទៅជួបប្រធានដើម្បីរាយការណ៍ពីករណីនេះ ។

– បើរកមិនឃើញមានឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ត្រូវជូនគាត់ទៅជួបប្រធានដើម្បីរាយការណ៍អំពីករណីនេះ ។

**អនុប្រធាន ត្រូវ**

- ហែកសន្លឹកឆ្នោតមួយ (១) សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត ។
- បោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នងនៃសន្លឹកឆ្នោត រួចបត់សន្លឹកឆ្នោតជាបួន (៤) ផ្នត់ ។
- ជូនសន្លឹកឆ្នោតនោះ និងឯកសារបញ្ជាក់អត្តសញ្ញាណទៅអ្នកបោះឆ្នោត ។
- ជម្រាបគាត់ថាមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត អំពីគណបក្សនយោបាយដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ ។
- ណែនាំអ្នកបោះឆ្នោតថា ៖
  - នេះគឺជាសន្លឹកឆ្នោត ។
  - ដើរចូលក្នុងបន្ទប់សម្ងាត់ដែលទំនេរ លាសន្លឹកឆ្នោត និងដាក់លើផ្ទាំងក្រដាសដែលបិទភ្ជាប់នៅលើផ្ទៃតុ ។
  - គូសសញ្ញាគាំទ្រមួយនៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយតែមួយគត់ដែលអ្នកពេញចិត្ត ដោយប្រើប៊ិចដែលមាននៅទីនោះស្រាប់ ឬប៊ិច ឬស្លាបប៉ាកាផ្ទាល់ខ្លួន លើកលែងតែខ្មៅដៃ ។
  - ពិចារណាឱ្យហ្មត់ចត់មុននឹងគូសសញ្ញាគាំទ្រដើម្បីបង្ការការខូចសន្លឹកឆ្នោត ដោយសារការផ្លាស់ប្តូរចិត្តបន្ទាប់ពីគូសរួច ។
  - មុននឹងចេញពីបន្ទប់សម្ងាត់ ត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ ។
  - ចេញពីបន្ទប់សម្ងាត់ដើរតម្រង់ទៅតុដាក់ហិបឆ្នោត បង្ហាញសន្លឹកឆ្នោតដែលបត់រួចនោះដោយដាក់ផ្នែកដែលមានត្រាសម្ងាត់បែរទៅរកជំនួយការទី១ រួចស៊កសន្លឹកឆ្នោតតាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។
- ផ្តល់សន្លឹកឆ្នោតមួយ (១) សន្លឹកថ្មីទៀត ចំពោះអ្នកបោះឆ្នោតដែលបានធ្វើឱ្យខូច ឬហែកដោយអចេតនាតាមការអនុញ្ញាតពីប្រធាន ។

**ចំណាំ** ៖ _ មិនត្រូវប្រគល់សន្លឹកឆ្នោត និងអនុញ្ញាតឱ្យអ្នកបោះឆ្នោតបន្ទាប់ចូលក្នុងបន្ទប់សម្ងាត់ទេ ប្រសិនបើអ្នកបោះឆ្នោតមុន មិនទាន់បានចេញផុតពីបន្ទប់សម្ងាត់ ។

_ មិនត្រូវយកសៀវភៅសន្លឹកឆ្នោតធ្វើជាទ្រនាប់សម្រាប់បោះត្រាសម្ងាត់ និងបត់សន្លឹកឆ្នោតឡើយ (បង្ការការប្រឡាក់ទឹកត្រាលើសន្លឹកឆ្នោតផ្សេងទៀត) ។

_ មិនអនុញ្ញាតឱ្យហែកសន្លឹកឆ្នោត និងបោះត្រាសម្ងាត់ទុកមុន ។



**អនុប្រធានបត់សន្លឹកឆ្នោតឱ្យបានបួនផ្នត់តាមការណែនាំមុននឹងហុចឱ្យអ្នកបោះឆ្នោត**



**របៀបបត់សន្លឹកឆ្នោតឱ្យបានបួនផ្នត់ដើម្បីឱ្យរូបសញ្ញាត្រាសម្ងាត់ស្ថិតនៅខាងក្រៅ**

**ជំនួយការទី ១ ត្រូវ**

- ពិនិត្យឱ្យប្រាកដថាជាសន្លឹកឆ្នោតផ្លូវការតែមួយ (១) សន្លឹក និងមានត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតនៅខាងខ្នង នៅពេលដែលអ្នកបោះឆ្នោតលើកសន្លឹកឆ្នោតបង្ហាញមុននឹងសិកទៅក្នុងហិបឆ្នោត ។
- ជូតម្រាមចង្អុលដៃស្ដាំអ្នកបោះឆ្នោតឱ្យស្អាត ដោយកំណាត់ដែលមានស្រាប់ បើគ្មានម្រាមចង្អុលដៃស្ដាំ ប្រើម្រាមដៃបន្តបន្ទាប់ ឬម្រាមចង្អុលដៃឆ្វេង ឬម្រាមដៃបន្តបន្ទាប់ ឬផ្នែកអវៈយវៈ ណាមួយ ។
- កាន់ និងជ្រលក់ម្រាមដៃដែលជូតហើយនោះទៅក្នុងដបទឹកខ្មៅលុបលាងមិនជ្រះឱ្យលិចដល់គល់ក្រចក ទុកឱ្យស្ងួតរយៈពេល ៣០ វិនាទី ទើបឱ្យគាត់ចេញពីការិយាល័យ ។
- បិទគម្របទឹកខ្មៅឱ្យជិត រួចក្រឡុករាល់ ៣០ នាទី ម្ដង ។
- បិទគម្របទឹកខ្មៅដើម្បីការពារកុំឱ្យហួត បើគ្មានអ្នកបោះឆ្នោតក្នុងរយៈពេលយូរគួរសម ។
- បម្រុងទុកទឹកខ្មៅលុបលាងមិនជ្រះមួយ (១) ដប ទៀតសម្រាប់ប្រើនៅពេលអស់ទឹកខ្មៅលុបលាងមិនជ្រះនៃដបទី ១ ។



**ជំនួយការទី ១**
**ណែនាំឱ្យអ្នកបោះឆ្នោតជ្រលក់ម្រាមចង្អុលដៃស្តាំ**

**ចំណាំ** ៖
- ត្រូវថែរក្សាឱ្យកំប៉ុង ឬដបជ័រ (កាត់ខ្លី) ដាក់ដីខ្សាច់សម្រាប់ដាក់ទប់ដបទឹកខ្មៅលុបលាងមិនជ្រះដើម្បីរក្សាលំនឹងជៀសវាងការដួលកំពប់ ។
- រាយការណ៍ជាបន្ទាន់ជូនប្រធាន បើឃើញអ្នកបោះឆ្នោតណាមានបំណងស៊កសន្លឹកឆ្នោត លើសពីមួយ (១) សន្លឹក ឬស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត ។
- ត្រូវមួលភ្ជិតសន្ទះប្រឡោះស៊កសន្លឹកឆ្នោតជាបណ្តោះអាសន្ន បើគ្មានអ្នកបោះឆ្នោតមកបោះឆ្នោតទេនោះ និងត្រូវបើកសន្ទះវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត ។

**៦- ការងាររបស់ប្រធានក្នុងពេលមានករណីផ្សេងៗកើតឡើងនៅពេលបោះឆ្នោត**

**ក- ករណី អ្នកបោះឆ្នោតមានស្នាមទឹកខ្មៅលុបលាងមិនជ្រះជាប់នៅលើម្រាមដៃ**

| ប្រធាន គកប ត្រូវ | |
|---|---|
| | - អញ្ជើញតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ឱ្យមកកត់សម្គាល់បញ្ហានេះ ។<br>- ឱ្យអ្នកបោះឆ្នោតនោះពន្យល់បំភ្លឺអំពីបញ្ហានេះ បើការបំភ្លឺនោះមិនសមហេតុផល សន្និដ្ឋានថាគាត់មានបំណងបោះឆ្នោតលើសពីមួយ (១) ដង ដែលត្រូវទទួលទោសតាមច្បាប់ ។<br>- ដកហូតឯកសារបញ្ជាក់អត្តសញ្ញាណជាបណ្តោះអាសន្ន រួចបញ្ជូនទៅ គឃ/សប ដើម្បីចាត់វិធានការបន្តទៀត ។<br>- ចាត់លេខាធិការឱ្យកត់ត្រាហេតុការណ៍នេះនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងស្រង់ឈ្មោះ ទិន្នន័យពីក្នុងឯកសារបញ្ជាក់អត្តសញ្ញាណ សម្រាប់ការតាមដានបន្ថែមទៀត ។<br>- បើគាត់មិនយល់ព្រមតាមវិធានការខាងលើ ប្រធាន គកប ឬ គឃ/សប ស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។ |

**ខ- ករណី លេខាធិការរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមិនឃើញ**

**ប្រធាន គកប ត្រូវ**

- ជម្រាបគាត់ថា គាត់ពុំអាចបោះឆ្នោតនៅការិយាល័យនេះបានទេ ព្រោះគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យនេះ ឬ
- សួររកបណ្ណព័ត៌មានរបស់គាត់ ដើម្បីជម្រាបគាត់អំពីទីតាំងការិយាល័យបោះឆ្នោតដែលគាត់ត្រូវបោះឆ្នោតប្រសិនជាករណីច្រឡំការិយាល័យ ។
- ជម្រាបគាត់ឱ្យចេញពីការិយាល័យបោះឆ្នោត ។

**គ- ករណី អ្នកបោះឆ្នោតមានបំណងស៊កសន្លឹកឆ្នោតលើសពីមួយ (១) សន្លឹក ឬ/និងសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងៗទៀត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យ**

- ចំពោះអ្នកបោះឆ្នោតមិនមែនជាបេក្ខជនឈរឈ្មោះ

**ប្រធាន គកប ត្រូវ**

- ឃាត់អ្នកបោះឆ្នោតនោះមិនឱ្យបោះឆ្នោត ។
- ប្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត មុននឹងមានវិធានការឆែកឆេររកសន្លឹកឆ្នោតផ្លូវការ ។
- ដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវទាំងនោះ និងឆែកឆេររកសន្លឹកឆ្នោតផ្លូវការ (ប្រសិនបើមាន) ដាក់ក្នុងស្រោមសំបុត្រមានកាខ្ទងស្រាប់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " ។
- ដកហូតឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការជាបណ្តោះអាសន្ន ។
- ចាត់ចែងធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទ ប្តឹងចោទប្រកាន់ជនល្មើសទៅ គឃ/សប ។
- អ្នកបោះឆ្នោតនោះត្រូវតែមានទោសដោយផ្អែកតាម ច.ប.ត.រ ។

- ប្រសិនបើជនប្រព្រឹត្តល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយបើមានភស្តុតាងគ្រប់គ្រាន់ គឃ/សប ត្រូវប្តឹងបន្តទៅ គជ/ខប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

**ឃ- ករណី អ្នកបោះឆ្នោតពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន**

អ្នកបោះឆ្នោតពិការដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន អាចជ្រើសរើសអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬអាចស្នើសុំជំនួយពីប្រធាន គកប ។ ប្រធាន គកប ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនពិការនោះ ឬអាចចាត់សមាជិក គកប ណាម្នាក់ជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួន។

- អ្នកជំនួយជនពិការ ត្រូវសួរអ្នកបោះឆ្នោតជាជនពិការថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយមួយណា ?
- អ្នកជំនួយត្រូវសួរតិចៗធ្វើយ៉ាងណាកុំឱ្យមនុស្សដែលនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ ។
- អ្នកជំនួយត្រូវគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយដែលអ្នកបោះឆ្នោតពិការជ្រើសរើស ហើយបត់សន្លឹកឆ្នោតនោះតាមផ្នត់ដើម រួចត្រូវនាំអ្នកបោះឆ្នោតទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់ចូលទៅក្នុងហិបឆ្នោត ។
- អ្នកជំនួយជនពិការត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់ ។

**ង- ករណី អ្នកបោះឆ្នោតពិការភ្នែកទាំងសងខាង**

ចំពោះអ្នកបោះឆ្នោតជាជនពិការភ្នែកទាំងសងខាង ដែលមានបំណងបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ប្រធាន គកប ត្រូវណែនាំអ្នកបោះឆ្នោតនេះឱ្យប្រើក្របក្រដាសពិសេស ដែលមានចោះប្រហោងរាងបួនជ្រុងទ្រវែង ទំហំប៉ុនគ្នានៅចំប្រអប់គូសសញ្ញាគាំទ្រគណបក្សនយោបាយនៅលើសន្លឹកឆ្នោត។ អ្នកបោះឆ្នោតពិការភ្នែកទាំងសងខាង ត្រូវស្ទាប និងគូសសញ្ញាគាំទ្រក្នុងប្រហោងរាងបួនជ្រុងទ្រវែង ដែលចំប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយណាមួយដែលគាត់ពេញចិត្ត ។

**ច- ករណី អ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប៉ុនប៉ងចង់ឃើញអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រគណបក្សនយោបាយ**

**ប្រធាន គកប ត្រូវ** ⇨

- ព្រមានផ្ទាល់មាត់ ចំពោះការប៉ុនប៉ងលើកទី ១ ។
- ចាត់ទុកជាការរំលោភលើភាពសម្ងាត់នៃការបោះឆ្នោត ត្រូវបណ្តេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ត.រ ចំពោះការប៉ុនប៉ងលើកទី ២ ។
- ចាត់លេខាធិការឱ្យកត់ត្រាហេតុការណ៍នេះក្នុងកំណត់ហេតុមួយដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត ។
- បញ្ជូនកំណត់ហេតុជូន គឃ/សប ក្នុងករណីជនប្រព្រឹត្តល្មើសគោលការណ៍សម្ងាត់នៃការបោះឆ្នោតនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

▪ បន្ទាប់ពីបានទទួលកំណត់ហេតុខាងលើ គឃ/សប ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ ។

▪ បើមានភស្តុតាងបញ្ជាក់ថា មានអំពើរំលោភពិតប្រាកដមែន គឃ/សប ត្រូវបញ្ជូនករណីនេះទៅ គធ/ខប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

**ឆ-   ករណី សន្លឹកឆ្នោតខូច   ឬរហែកដោយអចេតនា   ឬដែលបានគូសសញ្ញាលើសន្លឹកឆ្នោតខូចហើយតែបានផ្លាស់ប្តូរចិត្តវិញ**

**ប្រធាន គកប ត្រូវ** ⇨

- អនុញ្ញាតឱ្យអនុប្រធានផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតមួយសន្លឹកទៀត ហើយ ឱ្យតែមួយ (១) លើកនេះគត់ ។
- ប្រាប់គាត់ឱ្យបត់សន្លឹកឆ្នោតខូច ឬរហែក ឬផ្លាស់ប្តូរចិត្តតាមផ្នត់ដើម ។
- ដាក់សន្លឹកឆ្នោតខូច ឬរហែក ឬផ្លាស់ប្តូរចិត្តទៅក្នុងស្រោមសំបុត្រដែលមាន កាខ្វងស្រាប់ "សន្លឹកឆ្នោតខូច" ហើយឱ្យលេខាធិការកត់ត្រាបញ្ហាទាំងនេះចូល ក្នុង ទ.១១០១ ។
- សម្រេចមិនព្រមផ្តល់សន្លឹកឆ្នោតមួយ (១) សន្លឹកផ្សេងទៀតតាមការស្នើសុំបាន ឡើយ ប្រសិនបើអ្នកបោះឆ្នោតមកសុំបន្តបន្ទាប់គ្នាដែលចាត់ទុកថាជាភាពមិន ប្រក្រតី ហើយឱ្យលេខាធិការកត់ត្រាបញ្ហានេះក្នុង ទ.១១០១ ។
- រំលឹកអនុប្រធានឱ្យណែនាំអ្នកបោះឆ្នោត អំពីរបៀបបង្ការសន្លឹកឆ្នោតខូច ។
- ធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់ សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

**ជ-   ករណី មានការជំទាស់ពីតំណាងគណបក្សនយោបាយណាម្នាក់ក្នុងពេលបោះឆ្នោត**

**ប្រធាន គកប ត្រូវ** ⇨

- ឱ្យតំណាងគណបក្សនយោបាយលើកការជំទាស់នោះ មកខ្លួនផ្ទាល់ ។
- ឱ្យបង្ហាញពីមូលហេតុ ឬភស្តុតាងដែលគាត់ជឿថាមានភាពមិនប្រក្រតី ឬមានការរំលោភលើច្បាប់ ឬបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ។

- បើជំទាស់សមហេតុផល

**ប្រធាន គកប ត្រូវ** ⇨

- ផ្អាកជាបណ្តោះអាសន្ន កិច្ចប្រតិបត្តិការបោះឆ្នោត ។
- ស្តាប់ការជំទាស់នោះ ។
- ពិភាក្សាជាមួយសមាជិក គកប ដទៃទៀត ។
- សម្រេចយល់ព្រម ឬបដិសេធការជំទាស់នោះ ។

- បើយល់ព្រមតាមការជំទាស់នោះ ប្រធានត្រូវរំលឹក និងណែនាំសមាជិក គកប និងអ្នកមាន វត្តមានក្នុងការិយាល័យ អំពីខ្លឹមសារពាក់ព័ន្ធ ហើយត្រូវរិះរកវិធីដើម្បីដោះស្រាយភាពមិន ប្រក្រតីនោះ ។
- បើបដិសេធការជំទាស់ ៖
  - ផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធ ។
  - ឱ្យលេខាធិការកត់ត្រាការជំទាស់នោះទៅក្នុង ទ.១១០១ ប្រសិនបើតំណាងគណបក្សនោះ សុំឱ្យកត់ត្រា និងយល់ព្រមផ្តិតមេដៃនៅលើ ទ.១១០១ ។ បើគាត់មិនយល់ព្រមផ្តិតមេដៃ មិនត្រូវកត់ត្រានៅក្នុង ទ.១១០១ ទេ ។
  - ប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត ។
  - ផ្តល់ ទ.១២០២ ជូនគាត់សម្រាប់ប្តឹងទៅ គឃ/សប (ប្រសិនបើគាត់សុំ) ។

**ចំណាំ ៖** – សេចក្ដីសម្រេចរបស់ប្រធាន គកប ត្រូវតែមានប្រសិទ្ធភាព ។

– អ្នកជំទាស់មិនត្រូវជ្រៀតជ្រែក និងរំខានកិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

**ឈ- ករណី មានអ្នកបោះឆ្នោតរំខានធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត ( ទោះបីនៅក្នុងការិយាល័យបោះឆ្នោតក្ដី ឬកំពុងឈរជាជួរនៅក្នុងបរិវេណខាងក្នុងក្ដី )**

| ប្រធាន គកប ត្រូវ | - បញ្ជាអ្នកបោះឆ្នោតនោះឱ្យចេញទៅក្រៅការិយាល័យបោះឆ្នោត និងចេញឱ្យផុតពីបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ។<br>- បើគាត់មិនព្រមចេញ ត្រូវស្នើកម្លាំងសន្តិសុខ ឱ្យបណ្ដេញបុគ្គលនោះចេញ ឬឃាត់ខ្លួនរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។ |
|---|---|

**ញ- ករណី កិច្ចប្រតិបត្តិការបោះឆ្នោតត្រូវរំខានដល់កម្រិតដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបានតទៅទៀត**

ប្រធាន គកប អាចស្នើសុំកម្លាំងសន្តិសុខ ឱ្យរៀបចំសាឡើងវិញនូវរបៀបរៀបរយនៅខាងក្នុង និងខាងក្រៅការិយាល័យបោះឆ្នោត ។

- សកម្មភាពរំខានដល់កម្រិតមិនអាចបោះឆ្នោតបានមាន ៖
  - ការបញ្ចេញពាក្យសំដីគំរាមកំហែង ឬជេរប្រមាថ មាក់ងាយ ។
  - ការបញ្ចេញសម្រែកខ្លាំងៗ ។
  - ការរុញច្រានដោយប្រើកម្លាំងធ្ងន់ ។
  - ការគប់វត្ថុផ្សេងៗ សំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត ។
  - ការអុកឡុកដោយបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត ។
  - ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ ។
  - ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗប្រកបដោយគ្រោះថ្នាក់ ។

**ដ- ករណី ការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោងបី (៣:០០) រសៀល ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត**

| ប្រធាន គកប ត្រូវ | - ចាត់ជំនួយការទី ២ ឱ្យដើរប្រមូលឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការពីអ្នកបោះឆ្នោត ដែលកំពុងឈរក្នុងជួរ ដោយចាប់ផ្ដើមប្រមូលពីអ្នកឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ជូនសមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ ។<br>- ចាត់សមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ឱ្យហៅឈ្មោះម្នាក់ម្ដងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោតតាមលំដាប់លំដោយ និងតាមនីតិវិធី ។ |
|---|---|

**ចំណាំ** ៖ - បើអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនទាន់បានបោះឆ្នោតគ្រប់គ្នាទេនោះ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី ប្រធាន គកប មិនអាចបិទការបោះឆ្នោតនៅការិយាល័យរបស់ខ្លួន នៅមុនម៉ោង ៣:០០ រសៀល បានឡើយ ។

- បើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានមកបោះឆ្នោតគ្រប់គ្នាអស់ហើយ ប្រធាន គកប អាចប្រកាសបិទការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ៣:០០ រសៀលបាន។
- អ្នកបោះឆ្នោតណាដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងជួរអ្នកបោះឆ្នោត ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅនាទីចុងក្រោយនាម៉ោងបី (៣:០០) រសៀលនៃថ្ងៃបោះឆ្នោតទេនោះ អ្នកបោះឆ្នោតនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

**ប់- ករណី ប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត ឬ/និងក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅមុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត**

**ប់-១ ករណីមិនបើកការិយាល័យបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត**

| ប្រធាន គកប ត្រូវ | - រាយការណ៍ជាបន្ទាន់ជូន គឃ/សប ដើម្បី គឃ/សប រាយការណ៍បន្តទៅ គធ/ខប ហើយ គធ/ខប រាយការណ៍ជូន គ.ជ.ប ។<br>- សម្រេចមិនបើកការិយាល័យរបស់ខ្លួន ដោយផ្អែកតាមការកំណត់របស់ គ.ជ.ប។ |
|---|---|

**ប់-២ ករណី ការិយាល័យបោះឆ្នោតមិនបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត ប្រធាន គកប ត្រូវ ៖**

- សម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោត និងរាយការណ៍ជាបន្ទាន់ជូន គឃ/សប ដែលត្រូវរាយការណ៍បន្តតាមលំដាប់ថ្នាក់ទៅ គធ/ខប និង គ.ជ.ប (ការិយាល័យបោះឆ្នោតមិនបានបើក ឬត្រូវបិទ ត្រូវតែបិទពេញមួយថ្ងៃ រហូតដល់មានការសម្រេចជាថ្មី) ។
- ចាត់ចែងបញ្ជូនសម្ភារ ឯកសារបោះឆ្នោតទាំងអស់ទៅ គឃ/សប (សម្រាប់ការិយាល័យបោះឆ្នោតមិនបើក)
- ចាត់ចែងវេចខ្ចប់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង សន្លឹកឆ្នោតមិនទាន់ប្រើ និងសម្ភារឯកសារបោះឆ្នោតផ្សេងទៀត (សម្រាប់ការិយាល័យបោះឆ្នោតបានបិទ បន្ទាប់ពីដំណើរការមួយរយៈ)
- ចាត់ចែងបំពេញ ទ.១១០៧ ចំនួនពីរ (២)ច្បាប់ ក្នុងនោះជូន គឃ/សប មួយ (១)ច្បាប់ និង គកប រក្សាទុកមួយ (១)ច្បាប់ ។
- ចាត់ចែងធ្វើកំណត់ហេតុដោយឡែកស្តីពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតនោះ

- បញ្ជូនកំណត់ហេតុមក គឃ/សប រួមជាមួយនឹងសម្ភារ ឯកសារបោះឆ្នោតដែលបានវេចខ្ចប់នោះ ។
- សន្លឹកឆ្នោតដែលបានបោះរួចមានក្នុងហិបឆ្នោត និងសន្លឹកឆ្នោតមិនទាន់ប្រើត្រូវទុកជាមោឃៈ ។

**ច-៣ ករណីកាលៈទេសៈមានអាសន្នកើតឡើងក្រោយពេលបិទការបោះឆ្នោត តែសម្ភារឯកសារត្រូវខូចខាត**

ករណីកាលៈទេសៈមានអាសន្នកើតឡើងនៅការិយាល័យបោះឆ្នោតក្រោយពេលបិទការបោះឆ្នោត និងធ្វើកំណត់ហេតុរួច ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងឯកសារបោះឆ្នោតត្រូវខូចខាត គកប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គឃ/សប ក្នុងនោះ ប្រធាន គកប ត្រូវ ៖

- ធ្វើរបាយការណ៍ពីសភាពការណ៍ជាក់ស្តែងជូន គឃ/សប ។
- ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតទាំងនោះអមដោយរបាយការណ៍ជូន គឃ/សប ។
- បំពេញលិខិតបញ្ជូន និងប្រគល់ទទួល (ទ.១១០៧) ពីរ(២)ច្បាប់ ប្រើពេលប្រគល់ ទទួលក្នុងនេះ គឃ/សប រក្សាទុកមួយ (១)ច្បាប់ និង គកប រក្សាទុកមួយ (១)ច្បាប់ ។

**ច-៤ ករណីកាលៈទេសៈមានអាសន្នកើតឡើងក្រោយពេលបិទការបោះឆ្នោត តែសម្ភារឯកសារនៅល្អ**

ករណីកាលៈទេសៈមានអាសន្នកើតឡើងនៅការិយាល័យបោះឆ្នោត ក្រោយពេលបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួចហើយ ហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងឯកសារបោះឆ្នោតនៅរក្សាបានល្អ គកប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គឃ/សប ដើម្បីចាត់ចែងរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ/សប ឬនៅទីតាំងសុវត្ថិភាព ។ ក្នុងនោះ ប្រធាន គកប ត្រូវ ចាត់ចែងវេចខ្ចប់ និងបញ្ជូនជាបន្ទាន់ទៅ គឃ/សប នូវ ៖

- ហិបឆ្នោតដែលបានបិទភ្ជិត និងចាក់សោឃ្លុំមានលេខ ។
- វេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " តែមិនចាំបាច់បិទការសុវត្ថិភាពទេ ដាក់ក្នុងកញ្ចប់ " ខ " រួចចាក់សោឃ្លុំមានលេខ ។
- វេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ដោយឡែក ។
- បំពេញលិខិតបញ្ជូន និងប្រគល់ទទួល (ទ.១១០៧) ចំនួនពីរ(២)ច្បាប់ ប្រើពេលប្រគល់ ទទួលក្នុងនេះ គឃ/សប រក្សាទុកមួយ(១)ច្បាប់ និង គកប រក្សាទុកមួយ(១)ច្បាប់ ។
- បញ្ជូន និងប្រគល់ហិបឆ្នោត កញ្ចប់ "ខ" និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គឃ/សប ។ ក្នុងការបញ្ជូនត្រូវមានការអមដំណើរដោយអនុប្រធាន និងមន្ត្រី គកប មួយចំនួន តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងកម្លាំងសន្តិសុខពីរ(២)នាក់ផង ។

**ចំណាំ** ប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នត្រូវបានកំណត់ដូចខាងក្រោម ៖

- ការរញ្ជួយផែនដី ទឹកជំនន់ ភាពរាំងស្ងួត អគ្គិភ័យ ខ្យល់ព្យុះ ជំងឺរាតត្បាត
- សង្គ្រាម សង្គ្រាមស៊ីវិល ការបះបោរ
- ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោត ឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់ ។

- ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន ។

## V. ការបិទការបោះឆ្នោត នៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត

នៅពេលអ្នកបោះឆ្នោតចុងក្រោយបំផុតបានបោះឆ្នោតរួច ហើយចេញផុតពីការិយាល័យបោះឆ្នោត ប្រធាន គកប ត្រូវចាត់សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ឱ្យចាត់វិធានការចាំបាច់ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោត កុំឱ្យអ្នកគ្មានភារកិច្ចចេញចូល ។ បន្ទាប់មកប្រធាន គកប ត្រូវប្រកាសបិទការបោះឆ្នោតចំពោះមុខសមាជិក គកប តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអនុវត្តការងារជាបន្តបន្ទាប់ដូចតទៅ ៖

**ប្រធាន គកប ត្រូវ** ⇨

- មូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំង ២ នៃហិបឆ្នោត ។
- ចុះហត្ថលេខាលើក្រដាសស្តើងមួយសន្លឹក និងឱ្យតំណាងគណបក្សនយោបាយ ចុះហត្ថលេខាផង (ប្រសិនបើគាត់យល់ព្រម) រួចបិទពាសពីលើសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោតទាំង២ នោះ ។
- បិទគម្របខាងក្រៅនៃហិបឆ្នោត រួចចាក់សោឃ្លុំមានលេខនៅត្រង់ក្រវិលទាំង២ នៃហិបឆ្នោត និងអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ បានពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំង២នោះ ។
- ចាត់លេខាធិការឱ្យកត់ត្រាពេលវេលានៃការបិទការបោះឆ្នោត ព្រមទាំងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំង២ នៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ។
- ចាត់វិធានការការពារហិបឆ្នោតយ៉ាងហ្មត់ចត់ ។

## ១- ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច

**ប្រធាន គកប ត្រូវ** ⇨

- ចាត់លេខាធិការឱ្យរាប់ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតដោយរាប់ចំនួនគំនូសសញ្ញាដែលបានគូសសម្គាល់ក្នុងបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ។
- ឱ្យអនុប្រធានខណ្ឌសម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតមិនបានប្រើ រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងរាប់ចំនួនសន្លឹកឆ្នោតខូចដោយឡែកពីគ្នា ។
- ឱ្យលេខាធិការ និងអនុប្រធានធ្វើការផ្ទៀងផ្ទាត់គ្នា ប្រសិនបើឃើញថា ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដកផលបូកនៃចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច មានចំនួនស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនោះ ត្រូវចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនស្មើគ្នានោះនៅក្នុង ទ.១១០១ ។
- ប្រសិនបើឃើញថាមានភាពខុសគ្នា ៖
  - ចាត់លេខាធិការឱ្យរាប់ចំនួនគំនូសសញ្ញាសម្គាល់អ្នកបោះឆ្នោតដែលបានមកបោះឆ្នោតជាលើកទី២ ។
  - ឱ្យអនុប្រធានផ្ទៀងផ្ទាត់ និងរាប់ឡើងវិញដែរនូវចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច
- ប្រសិនបើឃើញថា នៅតែមានភាពខុសគ្នាទៀត ៖
  - ចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនដែលខុសគ្នានោះនៅក្នុង ទ.១១០១ ។
  - បន្តចាត់ចែងអនុវត្តតាមនីតិវិធីជាបន្ត ។
- ចាត់ជំនួយការទី២ ឱ្យចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើទាំងអស់ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ ។
- ឱ្យអនុប្រធានដាក់សន្លឹកឆ្នោតមិនបានប្រើដែលត្រូវបានចោះរន្ធ ឬកាត់រួចហើយ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងប្លាស្ទិកតែមួយ រួចបិទឱ្យជិត ។

## ២- រូបមន្តផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត

| ចំនួនអ្នកបោះឆ្នោត ដែលបានបោះឆ្នោត | = | ចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្តែង | - | ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ + ចំនួនសន្លឹកឆ្នោតខូច |
|---|---|---|---|---|

### ៣- កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងការប្រើប្រាស់

**ប្រធាន គកប ត្រូវ**

- ចាត់លេខាធិការឱ្យកត់ត្រាបន្ថែមនូវលេខសោឃ្លុំដែលនឹងត្រូវប្រើប្រាស់សម្រាប់ចាក់ឃ្លុំមាត់កញ្ចប់ " ខ " នៅក្នុង ទ.១១០១ ផងដែរ និងបោះត្រាសម្ងាត់នៅជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ។
- ឱ្យលេខាធិការចុះហត្ថលេខាលើ ទ.១១០១ ទាំង ៣ ច្បាប់ ។
- ពិនិត្យរួចចុះហត្ថលេខាលើ ទ.១១០១ ទាំង ៣ ច្បាប់ រួចឱ្យលេខាធិការបោះត្រាការិយាល័យលើ ទ.១១០១ ទាំង ៣ ច្បាប់ ដែលបានបំពេញរួច ។
- ដាក់បង្ហាញកំណត់ហេតុនេះដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ ។
- តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុនេះ ។
- ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុ ពីតំណាងគណបក្សនយោបាយណាម្នាក់មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានទេ ។

**- ទ.១១០១ = ៣ច្បាប់**

- ១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ពមានកាខ្ទងថា "កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើ ជូន គ.ជ.ប " ។
- ១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ពមានកាខ្ទងថា "កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការាប់សន្លឹកឆ្នោតផ្ញើជូន គធ/ខប " ។
- ១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ពមានកាខ្ទងថា "កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គឃ/សប ។

### ៤- ការវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " (មិនទាន់បិទភ្ជិតការសុវត្ថិភាព)

ប្រធាន គកប ត្រូវរៀបចំវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតរួចដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " ដែលមាន ៖

- ស្រោមសំបុត្រដាក់ ទ.១១០១ ផ្ញើជូន គ.ជ.ប ។
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោត ។
- ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច" ។
- ស្បោងប្លាស្ទិកដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " ។

- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។
- ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " ( ប្រសិនបើមាន ) ។
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត ( ប្រសិនបើមាន ) ។

**ចំណាំ** ៖

**ប្រធាន គកប ត្រូវ**

- ចាត់ចែងត្រួតពិនិត្យឱ្យបានហ្មត់ចត់ថា សម្ភារ ឯកសារខាងលើត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " គ្រប់សព្វហើយ ។
- កុំទាន់បិទការសុវត្ថិភាពកញ្ចប់សុវត្ថិភាព " ក " នៅពេលនេះ ព្រោះត្រូវរង់ចាំដាក់ ទ.១១០២ ទ.១១០៨ និងស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត ( ប្រសិនបើមាន) ចូលក្នុងកញ្ចប់សុវត្ថិភាព " ក " បន្ថែមទៀត នៅពេលដំណើរការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ ។
- សរសេរលេខកូដការិយាល័យលើកញ្ចប់សុវត្ថិភាព " ក " ផ្នែកខាងក្រៅ ដោយប៊ិចហ្វឺតលុបមិនជ្រះ ។
- ចាត់ចែងរក្សាទុកកញ្ចប់សុវត្ថិភាព " ក " យ៉ាងហ្មត់ចត់ និងមានសុវត្ថិភាពក្នុងពេលកំពុងដំណើរការរាប់សន្លឹកឆ្នោត ។

**( មិនទាន់បិទការសុវត្ថិភាព )**

**កញ្ចប់សុវត្ថិភាព " ក "**

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |

- ស្រោមសំបុត្រដាក់ ទ.១១០១ ផ្ញើជូន គ.ជ.ប ។
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត ។
- ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " ។
- ស្បោងប្លាស្ទិកដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " ។
- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។
- ស្រោមសំបុត្រដាក់ "សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត" ( ប្រសិនបើមាន) ។
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត( ប្រសិនបើមាន) ។

### ៥- ការរៀបចំទុកដាក់សម្ភារ ឯកសារនៅសល់ផ្សេងទៀត

ប្រធាន គកប ត្រូវចាត់ចែងសមាជិកឱ្យ ៖

- រៀបចំទុកដាក់សម្ភារ ឯកសារដែលនៅសល់ក្នុងកេសស័ង្កសី ។
- វេចខ្ចប់ដបទឹកខ្មៅលុបលាងមិនជ្រះដោយឡែក ។
- រុះរើបន្ទប់សម្ងាត់ទាំងពីរ (២) រួចច្រកទៅក្នុងការុងទីឡុងដែលបានប្រើសម្រាប់ដាក់បន្ទប់សម្ងាត់ដូចនៅពេលដែល គកប បានទទួលនាពេលដំបូង។
- រៀបចំទុកដាក់សម្ភារ ឯកសារខាងលើនោះឱ្យមានសុវត្ថិភាព នៅក្នុងការិយាល័យបោះឆ្នោត ។

## VI. ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតាមការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ លើកលែងតែការិយាល័យបោះឆ្នោតណាដែលមានសេចក្ដីសម្រេចផ្សេងពីនេះដោយ គ.ជ.ប ។ គកប ក្លាយជា គករ នៅពេលរាប់សន្លឹកឆ្នោត ។

ការរាប់សន្លឹកឆ្នោតត្រូវធ្វើបន្ទាប់ពីការបិទការបោះឆ្នោត និងការធ្វើកំណត់ហេតុនៃការបោះឆ្នោតចប់រួចរាល់នាល្ងាចនៃថ្ងៃបោះឆ្នោត ។

ការផ្ទៀងផ្ទាត់ និងការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតែមួយកន្លែងសម្រាប់ការិយាល័យបោះឆ្នោតមួយ ហើយឱ្យចប់ចុងចប់ដើម ដោយពុំត្រូវឈប់សម្រាកឡើយ ហើយធ្វើចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន ទ.១១១៥ នៅមុនពេលចាប់ផ្ដើមរាប់សន្លឹកឆ្នោត ហើយអាចផ្លាស់ប្ដូរតំណាងបម្រុងរបស់ខ្លួន (ប្រសិនបើមាន) ឱ្យជំនួសដើម្បីបន្តសង្កេតមើលដំណើរការនេះរហូតដល់ពេលបញ្ចប់ ។

អ្នកសង្កេតការណ៍ត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ។

ប្រធាន គករ ត្រូវចាត់ចែងរៀបចំបន្ទប់តាមគំរូប្លង់សម្រាប់ការរាប់សន្លឹកឆ្នោត និងមានវិធានការការពារសន្តិសុខក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

## ១- ការចាត់ចែងរៀបចំបន្ទប់រាប់សន្លឹកឆ្នោត

**ប្រធាន គករ ត្រូវ**

- ចាត់ចែងរៀបចំតាមប្លង់ការិយាល័យរាប់សន្លឹកឆ្នោត និងទុកដាក់សម្ភារ ឯកសារដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ។
- ចាត់ឱ្យរៀបតុធំមួយ ឬតុតូចច្រើនផ្គុំគ្នា និងកៅអីចំនួន៤ សម្រាប់សមាជិក គករ ដាក់ចំកណ្ដាលបន្ទប់ដែលអាចឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើរចុះឡើងជុំវិញតុដើម្បីសង្កេតមើលសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត ។
- ចាត់ឱ្យដាក់ផ្ទាំងក្រដាសធំមួយសន្លឹកលើជញ្ជាំង ឬលើក្ដារខៀន សម្រាប់កត់ត្រាសំឡេងឆ្នោត ។
- លើកហិបឆ្នោតដាក់ចំកណ្ដាលតុ និងដាក់កញ្ចប់សុវត្ថិភាព "ក" រាល់សម្ភារ ឯកសារ និងទម្រង់បែបបទរាប់សន្លឹកឆ្នោត ទ.១១០២ និងទម្រង់បែបបទចាំបាច់ផ្សេងៗ មកដាក់លើតុត្រង់កន្លែងខ្លួនអង្គុយ ។
- ត្រៀមភ្លើងសម្រាប់បំភ្លឺ ក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវអូសបន្លាយដល់ពេលយប់ ។
- អង្គុយចុងតុម្ខាងទល់មុខលេខាធិការ និងឱ្យអនុប្រធាន និងជំនួយការទី ១ អង្គុយអមសងខាងទល់មុខគ្នា ។
- ចាត់ជំនួយការទី២និងសមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលបើកចំហ កុំឱ្យមានអ្នកចេញចូលក្រៅពីអ្នកធ្វើការ ឬតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលត្រូវបានអនុញ្ញាត មើលថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោតដែលមិនត្រូវបានប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្ដាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

### គំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោត



**២- វិធានការចំពោះករណីអ្នកធ្វើសកម្មភាពមិនប្រក្រតី ដើម្បីចង់ដឹងអ្នកបោះឆ្នោតបានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយក្នុងពេលកំពុងរាប់សន្លឹកឆ្នោត**

ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោត ក្នុងពេលកំពុងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ហាមជនគ្រប់រូបធ្វើសកម្មភាព ទោះតាមរូបភាពណាក៏ដោយ ក្នុងគោលបំណងកត់សម្គាល់ដើម្បីឱ្យដឹងថា តើអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់បានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។

| | |
|---|---|
| **ប្រធាន គកស ត្រូវ** ⇨ | - ព្រមានផ្ទាល់មាត់ចំពោះការធ្វើសកម្មភាពលើកទី១ ។<br>- បណ្តេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ត.រ ចំពោះការធ្វើសកម្មភាពដដែលជាលើកទី២ ។<br>- ចាត់លេខាធិការឱ្យកត់ត្រាទុកហេតុការណ៍នេះក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត ។<br>- បញ្ជូនកំណត់ហេតុនេះជូន គឃ/សប ជាបន្ទាន់ ។ |

- នៅពេលទទួលបានកំណត់ហេតុនេះ គឃ/សប ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ ។
- បើមានភស្តុតាងបញ្ជាក់ថាមានអំពើរំលោភពិតប្រាកដមែន គឃ/សប ត្រូវបញ្ជូនករណីនេះទៅ គធ/ខប ដើម្បី គធ/ខប ចាត់វិធានការតាមផ្លូវច្បាប់ ។

**៣- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ**

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គកស ជាពិសេសប្រធាន អនុប្រធាន គកស ត្រូវយល់ដឹងយ៉ាងច្បាស់លាស់ អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

**ក- សន្លឹកឆ្នោតបានការ**

- សន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅតាមមណ្ឌលរាជធានី ខេត្តនីមួយៗ ។
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង ។
- សន្លឹកឆ្នោតមានគូសសញ្ញាគាំទ្រ ក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ។

**ខ- សន្លឹកឆ្នោតមិនបានការ**

សន្លឹកឆ្នោតមិនបានការត្រូវចាត់ទុកជាមោឃៈ មានប្រាំ(៥) ប្រភេទ ដូចខាងក្រោម ៖

**ខ-១ សន្លឹកឆ្នោតមិនផ្លូវការ ៖**

- សន្លឹកឆ្នោតមានខ្នាតតូច ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។

- សន្លឹកឆ្នោតដែលមានពណ៌ផ្សេង ខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។
- សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើន ដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅតាមមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ ។
- សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយ លើសពីចំនួនគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់មណ្ឌលនីមួយៗ ។
- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់មណ្ឌលនីមួយៗ ។
- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេង មិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គកប ពាក់ព័ន្ធ ។

**ខ-២.សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសតែ គករ ពុំអាចសន្និដ្ឋានថា បោះគាំទ្រគណបក្សនយោបាយណាមួយ ៖**

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ) ។
- សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយលើសពីមួយគណបក្ស ។
- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ ។

**ខ-៣.សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ ដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ៖**

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះបីនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោតក៏ដោយ ។
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះបីនៅក្នុង ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោតក៏ដោយ ។
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ ។
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត ។

**ខ-៤. សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច ៖**

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ។
- សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង ។
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅផ្នែកខាងមុខ ឬ/និងនៅផ្នែកខាងខ្នងដែលមិនអាចមើលឃើញនូវរូបសញ្ញា និងអក្សរដែលត្រូវបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយណាមួយ ។

**ខ-៥. សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ៖**

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

**ឧទាហរណ៍**

**ក- គំរូសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ព**




**ខ- គំរូសន្លឹកឆ្នោតមិនបានការត្រូវបានចាត់ទុកជាមោឃៈ**

**ខ-១ សន្លឹកឆ្នោតមិនផ្លូវការ**

សន្លឹកឆ្នោតទាំងឡាយណាដែលមិនបានផ្តល់ឱ្យជាផ្លូវការដោយមន្ត្រីការិយាល័យបោះឆ្នោត ឬមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ក្លែងបន្លំ មិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ រួមមាន ៖




១. សន្លឹកឆ្នោតមានខ្នាតតូចជាងសន្លឹកឆ្នោត ផ្លូវការរបស់ គ.ជ.ប




១.១. សន្លឹកឆ្នោតមានខ្នាតធំជាងសន្លឹកឆ្នោត ផ្លូវការរបស់ គ.ជ.ប




២. សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង ( ក្រាស់ជាង ឬស្តើងជាង ) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប




៣. សន្លឹកឆ្នោតដែលមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោត ផ្លូវការរបស់ គ.ជ.ប




៤. សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើនដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅតាមមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ




៥. សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់មណ្ឌលនីមួយៗ




៦. សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់មណ្ឌលនីមួយៗ



៧. សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គកប ពាក់ព័ន្ធ

## ខ-២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូស តែ គកស ពុំអាចសន្និដ្ឋានបានថាបោះគាំទ្រគណបក្សនយោបាយណាមួយ




១. សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់
(សន្លឹកឆ្នោតទំនេរ)




២. សន្លឹកឆ្នោតមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុង
ទ្រវែងនៃគណបក្សនយោបាយលើសពីមួយគណបក្ស




៣. សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់បួនជ្រុងទ្រវែង
នៃគណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មាន
គំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយក៏ដោយ

ខ-៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬ រូបភាពផ្សេងៗដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត




១. សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះបីនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និង នៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោតក៏ដោយ




២. សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះបីនៅក្នុង ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោតក៏ដោយ




៣. សន្លឹកឆ្នោតដែលមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ ភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត




៤. សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ




៥. សន្លឹកឆ្នោតមានសរសេរឈ្មោះ ហត្ថលេខា ឬសញ្ញា ដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត

ខ-៤ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច




១. សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ




២. សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង




៣. សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅផ្នែកខាងមុខ ឬ/និងនៅផ្នែកខាងខ្នងដែលមិនអាចមើលឃើញនូវរូបសញ្ញា និងអក្សរដែលត្រូវបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និង គំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយណាមួយ

ខ-៥ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ



១. សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ



២. សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ

## ៤- កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត

ប្រធាន គករ ត្រូវប្រកាសចាប់ផ្តើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន និងចាត់ចែងការងារ ដូចខាងក្រោម ៖

### ក- ការរៀបចំសម្ភារ ឯកសារ

ប្រធានគករ ត្រូវ ៖

**ដាក់ក្បែរខ្លួន**

- កញ្ចប់សុវត្ថិភាព " ក " ។
- ទ.១១១៥ សម្រាប់ស្រង់វត្តមានតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។
- ទ.១១២០ សម្រាប់ស្រង់វត្តមានអ្នកសង្កេតការណ៍ ។
- ទ.១២០២ សម្រាប់ជូនតំណាងគណបក្សនយោបាយ (ប្រសិនបើសុំ) ។
- ស្បោងប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ។
- កៅស៊ូកង ។

**ឱ្យអនុប្រធាន**

- តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួនមួយ (១) ច្បាប់ ។

**ឱ្យលេខាធិការ**

- ទ.១១០២ ចំនួនបួន (៤) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។
- តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួនមួយ(១) ច្បាប់ ។
- ស្រោមសំបុត្រដាក់ ទ.១១០១ ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព " ក " និងប្រាប់គាត់ឱ្យបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ចំនួនសន្លឹកឆ្នោតខូច និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតដែលមានកត់ត្រានៅក្នុង ទ.១១០១ ។

**ឱ្យជំនួយការទី១**

- ផ្ទាំងក្រដាសធំ ១ផ្ទាំង និងប៊ិចហ្វឺត ១ដើម សម្រាប់កត់ត្រាសំឡេងឆ្នោត ។

ខ- ការពិនិត្យហិបឆ្នោត (ចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍)

**ប្រធាន គកស ត្រូវ** ⇨

- ពិនិត្យផ្ទៀងផ្ទាត់ឱ្យច្បាស់ថាសោឃ្លុំទាំង ២ ដែលចាក់ជាប់គម្របខាងក្រៅនៃហិបឆ្នោត ស្ថិតក្នុងស្ថានភាពដើម ។
- កាត់ផ្តាច់សោឃ្លុំទាំង២ នេះដោយកន្ត្រៃ ឬកាំបិត បើកគម្របខាងក្រៅចេញ។
- ផ្ទៀងផ្ទាត់លេខសោឃ្លុំដែលចាក់ជាប់នឹងគន្លឹះខ្ទាស់បិទគម្របខាងក្នុងនៃហិបឆ្នោត និងក្រដាសស្អិតដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថាគ្មានការរុះរើ ។
- កាត់ផ្តាច់សោឃ្លុំ និងហែកក្រដាសបិទពាសនោះចោល ។
- បើកគម្របខាងក្នុងនៃហិបឆ្នោត ។
- ចាក់សន្លឹកឆ្នោត ឱ្យអស់ពីហិបឆ្នោតដាក់នៅលើតុត្រង់ចន្លោះអនុប្រធាន និងជំនួយការ ទី១ ។
- ដាក់ហិបឆ្នោតទទេនៅក្បែរខ្លួន ។




គ- ការរាប់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត

- ប្រធាន គកស ត្រូវ ៖

**ឱ្យជំនួយការទី១** ⇨

- រើសយកវត្ថុមិនមែនជាសន្លឹកឆ្នោតដែលមិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត (ប្រសិនបើមាន) ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ក្នុងស្រោមសំបុត្រមួយបម្រុងស្រាប់ ។

**ឱ្យលេខាធិការ** ⇨

- កត់ត្រាវត្ថុដែលមិនមែនជាសន្លឹកឆ្នោត( ប្រសិនបើមាន) ចូលក្នុង ទ.១១០២ ។

**ឱ្យអនុប្រធាន និង ជំនួយការទី ១** ⇨

- លា និងតម្រៀបសន្លឹកឆ្នោតដែលមានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង ដោយដាក់ផ្កាប់ចុះក្រោមជាបាច់ៗ ( ១បាច់ មាន ២៥ សន្លឹក ) ដាក់ក្នុងពំនូក ទី១ ។
- ដាក់សន្លឹកឆ្នោតគ្មានត្រាសម្ងាត់ផ្លូវការនៅខាងខ្នង ក្នុងពំនូកទី ២ ( ប្រសិនបើមាន ) ។
- រាប់ចំនួនសន្លឹកឆ្នោតទាំងពីរ (២) ពំនូក ឱ្យបានត្រឹមត្រូវ ។
- រាយការណ៍ជូនប្រធាន អំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ ។
- ហុចសន្លឹកឆ្នោតទាំងពីរ (២) ពំនូកនេះ ទៅប្រធាន ដែលគាត់ត្រូវដាក់ពំនូកទី ១ នៅខាងឆ្វេងដៃ និងពំនូកទី ២ នៅខាងស្តាំដៃគាត់ (ជូនប្រធានក្រោយពីបានផ្ទៀងផ្ទាត់រួច ) ។

**ឃ- ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត**

- អនុវត្តតាមរូបមន្ត ៖

**[ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោតនិងបានរាប់ឃើញសរុប] = [ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត]**

**ឬ**

**[ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោតនិងបានរាប់ឃើញសរុប] = [ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង] - [ចំនួនសន្លឹកឆ្នោតមិនបានប្រើ + ចំនួនសន្លឹកឆ្នោតខូច]**

- បើស្មើគ្នា លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននោះចូលក្នុង ទ.១១០២ ។
- បើខុសគ្នា ប្រធានត្រូវផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតឡើងវិញជាលើកទី២ យ៉ាងហ្មត់ចត់ ។
- បើនៅតែខុសគ្នាដដែល ៖

**ប្រធាន គករ ត្រូវ** ⇨

- ចាត់លេខាធិការឱ្យកត់ត្រាតួលេខដែលខុសគ្នានោះចូលក្នុង ទ.១១០២ ។
- ប្រកាសប្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនោះ ដើម្បីឱ្យអ្នកទាំងនោះបានដឹង និងងាយស្រួលក្នុងការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផល ។

**ង- ការកំណត់សុពលភាព និងការប្រកាសសន្លឹកឆ្នោតដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ**

ប្រធាន គករ ត្រូវយកសន្លឹកឆ្នោតមានត្រាសម្ងាត់ផ្លូវការនៅខាងខ្នង ១ សន្លឹកម្តងៗ រហូតដល់អស់សន្លឹកឆ្នោតពីពំនូកទី១ ដើម្បីពិនិត្យផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬមិនបានការ ។




**ការកំណត់សន្លឹកឆ្នោតបានការដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ**

- **សន្លឹកឆ្នោតបានការ**

**ប្រធាន គករ ត្រូវ** ⇨

- ប្រកាសឱ្យឮៗអំពីគណបក្សនយោបាយដែលសន្លឹកឆ្នោតនោះត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ ។
- កាន់បង្ហាញសន្លឹកឆ្នោតផ្នែកខាងមុខ ខាងខ្នង ឱ្យតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អាចបានឃើញច្បាស់ តែមិនអនុញ្ញាតឱ្យប៉ះពាល់ ឬកាន់សន្លឹកឆ្នោតឡើយ ។
- ដាក់សន្លឹកឆ្នោតបានការនោះ ទៅតាមពំនូកដោយឡែកៗ តាមគណបក្សនយោបាយពាក់ព័ន្ធនីមួយៗ ។
- ចាត់អនុប្រធាន និងលេខាធិការឱ្យគូសពិន្ទុមួយសម្រាប់សន្លឹកឆ្នោតមួយ(១) សន្លឹកដែលគណបក្សនយោបាយពាក់ព័ន្ធបានទទួល នៅក្នុងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ។
- ចាត់ជំនួយការទី១ ដោយប្រើប៊ិចហ្វឺតគូសពិន្ទុមួយនៅលើផ្ទាំងក្រដាសធំដែលដាក់លើជញ្ជាំង ឬក្ដារខៀន ។
- បើមានការជំទាស់ពីតំណាងគណបក្សនយោបាយក្នុងការកំណត់សុពលភាព ដាក់សន្លឹកឆ្នោតជំទាស់នោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដែលនឹងត្រូវយកមកពិនិត្យផ្ទៀងផ្ទាត់ម្ដងទៀតជាចុងក្រោយ ។

- **សន្លឹកឆ្នោតមិនបានការ**

**ប្រធាន គកស ត្រូវ** ⇨

- ប្រកាសឱ្យឮៗបញ្ជាក់ពីហេតុផលសម្រាប់សន្លឹកឆ្នោតមិនបានការនោះ ។
- លើកបង្ហាញតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ឱ្យធ្វើការត្រួតពិនិត្យសន្លឹកឆ្នោតមិនបានការនោះ ។
- ដាក់សន្លឹកឆ្នោតនោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ។

**ច- ការកំណត់សុពលភាពចុងក្រោយឆ្លងរាល់សន្លឹកឆ្នោតមិនបានការ**

ប្រធាន គកស ត្រូវយកសន្លឹកឆ្នោតមិនបានការនៅខាងស្តាំដៃមួយ (១)សន្លឹកម្តងៗរហូតដល់អស់សន្លឹកឆ្នោតពីពំនូកទី២ ដើម្បីពិនិត្យសុពលភាពជាចុងក្រោយ ។ បើពិនិត្យឃើញថាមិនច្បាស់លាស់ទៅលើសន្លឹកឆ្នោតណាមួយ ប្រធានត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គកស អំពីសុពលភាព និងការកំណត់ប្រភេទនៃសន្លឹកឆ្នោតនោះម្តងទៀត ដើម្បីកំណត់ចុងក្រោយថាពិតជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ ។

- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ប្រធានត្រូវអនុវត្តដូចចំណុច" **ង** "ខាងលើនេះ ។
- ករណីមានការមិនឯកភាពពីតំណាងគណបក្សនយោបាយណាម្នាក់ ទៅនឹងសេចក្តីសម្រេចរបស់ប្រធាន គកស ក្នុងការកំណត់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការនោះ ៖
  - តំណាងគណបក្សនោះមានសិទ្ធិលើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់នោះចូលក្នុង ទ.១១០២ ។
  - ប្រធាន គកស ត្រូវចាត់លេខាធិការឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនោះចូលក្នុង ទ.១១០២ បាន ប្រសិនបើតំណាងនោះយល់ព្រមផ្តិតមេដៃលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ។ បើគាត់មិនព្រមផ្តិតមេដៃ ប្រធានពុំបាច់ឱ្យកត់ត្រាខ្លឹមសារ និងហេតុផលទៅក្នុង ទ.១១០២ ឡើយ ។
  - សេចក្តីសម្រេចរបស់ប្រធាន គកស ត្រូវតែមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត ។
  - ប្រធាន គកស ត្រូវជូន ទ.១២០២ ចំនួនបី (៣) ច្បាប់ ដល់តំណាងគណបក្សនយោបាយនោះ (ប្រសិនបើគាត់សុំ) ដើម្បីប្តឹងទៅ គឃ/សប ។

**៥- ការបូកសរុបលទ្ធផល ការផ្ទៀងផ្ទាត់ និងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោត**

**ក- ការបូកសរុបលទ្ធផល**

**ប្រធាន គកស ត្រូវ** ⇨

- ឱ្យអនុប្រធាន និងលេខាធិការបូកសរុបលើ ទ.១១០៨
- ឱ្យជំនួយការទី ១ បូកសរុបលើផ្ទាំងក្រដាសធំ

⇨

- ចំនួនសន្លឹកឆ្នោតមិនបានការសរុប ។
- ចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ ។
- ចំនួនសន្លឹកឆ្នោតបានការសរុប ។
- ផ្ទៀងផ្ទាត់តួលេខគ្នា ។

| | |
|---|---|
| **ប្រធាន គកស ត្រូវ** ⇨ | - រាប់ចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ ។<br>- រាប់ចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់ ។<br>- ផ្ទៀងផ្ទាត់តួលេខខាងលើជាមួយតួលេខរបស់អនុប្រធាន លេខាធិការ និងជំនួយការទី១ ។<br>- បូកសរុបចំនួនសន្លឹកឆ្នោតបានការគ្រប់គណបក្សនយោបាយទាំងអស់ ។<br>- បូកសរុបបញ្ចូលគ្នាចំនួនសន្លឹកឆ្នោតបានការ និងចំនួនសន្លឹកឆ្នោតមិនបានការ ។ |

**ខ-រូបមន្តនៃការផ្ទៀងផ្ទាត់**

| | | |
|---|---|---|
| **ចំនួនសន្លឹកឆ្នោតបានការសរុប +<br>ចំនួនសន្លឹកឆ្នោតមិនបានការសរុប** | **=** | **ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត** |

- **បើឃើញស្មើគ្នា ៖**
  - ប្រធាន និងលេខាធិការចុះហត្ថលេខា បោះត្រាលើ ទ.១១០៨ ទាំងពីរ (២) ច្បាប់ និងលើផ្ទាំងក្រដាសធំ និងឱ្យតំណាងគណបក្សនយោបាយចុះហត្ថលេខាផងបើគាត់យល់ព្រម ។
  - ប្រធានប្រកាសជាចំហនូវលទ្ធផលនៃការរាប់សន្លឹកឆ្នោត ។
  - លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់ ទៅក្នុង ទ.១១០២ ។
- **បើឃើញមិនស្មើគ្នា ៖**
  - ករណីផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ មានចំនួនតិចជាង ឬច្រើនជាងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងដែលបានរាប់ឃើញ ៖

| | |
|---|---|
| **ប្រធាន គកស ត្រូវ** ⇨ | - រាប់ចំនួនសន្លឹកឆ្នោតបានការតាមពំនូកផ្សេងគ្នា សម្រាប់គណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការ រួចធ្វើប្រមាណវិធីឡើងវិញ។ បើនៅតែខុសគ្នាដដែល ម្យ៉ាងប្រសិនបើគ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោតទេ ឬ/និងគ្មានសន្លឹកឆ្នោតណាមួយ ត្រូវបានគេរកឃើញនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដោយសារការធ្លាក់ជ្រុះទេនោះ ត្រូវសន្មតថាភាពខុសគ្នានេះបានកើតឡើងមុនជាយថាហេតុ ។<br>- ចាត់លេខាធិការឱ្យកត់ត្រាតួលេខទាំងនោះចូលក្នុង ទ.១១០២។ |

- ក្រោយការផ្ទៀងផ្ទាត់ ៖

ប្រធាន គករ ត្រូវ ⇨

- ធានាថា សន្លឹកឆ្នោតបានការបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចង នឹងកៅស៊ូកងឱ្យជាប់ដោយឡែកពីគ្នា ។
- ធានាថា សន្លឹកឆ្នោតមិនបានការទាំងអស់ត្រូវបានចងនឹងកៅស៊ូកង និងដាក់ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្វងថា " សន្លឹកឆ្នោតមិនបានការ " ។

**៦- ការប្រើប្រាស់ ទ.១១០២ ទ.១១០៨ ទ.១១០៤ ទ.១១២០ និងការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោងប្លាស្ទិក**

**ក- ការប្រើប្រាស់ ទ.១១០២ ទ.១១០៨ ទ.១១០៤ ទ.១១២០**

**- ការប្រើប្រាស់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)**

ទ.១១០២ ចំនួនបួន (៤) ច្បាប់ ដែលចុះហត្ថលេខា ដោយលេខាធិការ និងប្រធាន គករ ព្រមទាំងបោះត្រាការិយាល័យផងនោះ ត្រូវបានប្រើប្រាស់ដូចខាងក្រោម ៖

ទ.១១០២ = ៤ ច្បាប់

- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ ដែលមាន ទ.១១០១ ចំនួន ១ច្បាប់ នៅក្នុងនោះស្រាប់ ហើយត្រូវដាក់ក្នុងកញ្ចប់សុវត្ថិភាព "ក" វិញ ផ្ញើជូន គ.ជ.ប ។
- ១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ ដែលមាន ទ.១១០១ ចំនួន ១ច្បាប់ នៅក្នុងនោះស្រាប់ ដើម្បីត្រៀមទុកដាក់ក្នុងកញ្ចប់ "ខ" ផ្ញើជូន គធ/ខប ។
- ១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ ដែលមាន ទ.១១០១ ចំនួន ១ច្បាប់ នៅក្នុងនោះស្រាប់ ដើម្បីត្រៀមទុកដាក់ក្នុងកញ្ចប់ "ខ" ផ្ញើជូន គឃ/សប ។
- ១ ច្បាប់ ឱ្យជំនួយការទី ២ បិទផ្សាយនៅត្រង់ច្រកចូលទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

**ចំណាំ** ៖
- ប្រធាន គករ ត្រូវបង្ហាញ ទ.១១០២ ឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បានឃើញ និងបានដឹង ព្រមទាំងអញ្ជើញតំណាងគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខាជាសាក្សី ។
- តំណាងគណបក្សនយោបាយអាចចុះហត្ថលេខា ឬផ្តិតមេដៃលើ ទ.១១០២ ជាសាក្សី ។ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុក ទ.១១០២ ជាមោឃៈបានទេ ។

- **ការប្រើប្រាស់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)**

ទ.១១០៨ ចំនួន ២ច្បាប់ ដែលចុះហត្ថលេខាដោយ លេខាធិការ និងប្រធាន គកស និងបោះត្រា ព្រមទាំងអាចចុះហត្ថលេខាពីតំណាងគណបក្សនយោបាយ ដែលមានវត្តមានផងនោះ ត្រូវបានប្រើប្រាស់ដូចខាងក្រោម ៖

ទ.១១០៨ = ២ ច្បាប់

- ១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ មានកាខ្ទង់ស្រាប់ដែលមាន ទ.១១០១ ទ.១១០២ នៅក្នុងនោះស្រាប់ហើយត្រូវដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " វិញ ផ្ញើជូន គ.ជ.ប ។
- ១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ មានកាខ្ទង់ស្រាប់ដែលមាន ទ.១១០១ ទ.១១០២ នៅក្នុងនោះស្រាប់ត្រៀមទុកដាក់ក្នុងកញ្ចប់ " ខ " ផ្ញើជូន គឃ/សប ។

- **ការប្រើប្រាស់ក្រដាសលទ្ធផលបឋម (ទ.១១០៤) និងបញ្ជីវត្តមានអ្នកសង្កេតការណ៍ (ទ.១១២០)**

ប្រធាន គកស ត្រូវចាត់ចែងលេខាធិការ ឱ្យបំពេញក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១១០៤) មួយចំនួន ដោយស្រង់តួលេខលទ្ធផលចេញពី ទ.១១០២ រួចចុះហត្ថលេខាដោយលេខាធិការ និងប្រធាន ព្រមទាំងបោះត្រាការិយាល័យផងសម្រាប់ចែកជូនតំណាងគណបក្សនយោបាយដែលមានវត្តមាន ។

ក្នុងការបំពេញ ទ.១១០៤ នោះ ប្រធាន គកស ត្រូវណែនាំសមាជិកឱ្យហែកទម្រង់នេះ (ក្រដាសអាចសរសេរផ្ទាម) ម្តងបី (៣) ច្បាប់ ចេញពីជុំរួចសិនមុននឹងសរសេរបំពេញ ។

ប្រធាន គកស ត្រូវចាត់ជំនួយការទី២ ឱ្យនាំយក ទ.១១០៤ មួយ(១)ច្បាប់ និង ទ.១១២០ មួយ (១)ច្បាប់ ទៅប្រគល់ ជូន គឃ/សប ជាបន្ទាន់ ។

## ខ- ការវេចខ្ចប់ស្បោងប្លាស្ទិក

